ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# អនាគតខ្ញុំ

## (ឯកសារសម្រាប់គ្រូ)



**បំណិនជីវិតសម្រាប់មធ្យមសិក្សាបឋមភូមិ**
**គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា**

USAID ជំនួយពីពលរដ្ឋអាមេរិក

អង្គការអប់រំពិភពលោក
WORLD EDUCATION

ឧបត្ថម្ភដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ
រៀបចំដោយ អង្គការអប់រំពិភពលោក សហការជាមួយអង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា

**គណៈកម្មការអភិវឌ្ឍសៀវភៅ**
**"អនាគតខ្ញុំ"**

**គណៈកម្មការនិពន្ធ និងរៀបរៀង**

១. លោកស្រី អេលិន ជោច (Eileen St. George)

២. លោក ចាន់ ណារិន

៣. លោក សៅ ប៊ុនធឿន

**គណៈកម្មការកែសម្រួល**

១. លោក ឈុំ វណ្ណឆន

២. លោកស្រី មុំ មេត

៣. លោក ប៉ុល សុរិទ្ធ

**គណៈកម្មការត្រួតពិនិត្យ**

១. លោក ព្រំ វិបុល

២. លោក មាស ជុតិមា

៣. លោក ហួត នរៈ

ឧបត្ថម្ភថវិកាដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិចដើម្បីអភិវឌ្ឍអន្តរជាតិ (USAID)

សហការរៀបចំដោយ

អង្គការអប់រំពិភពលោក និង ក្រសួងអប់រំ យុវជន និងកីឡា

# មាតិកា


អារម្ភកថា : ........................................................................ ១

លំណែនាំអនុវត្ត ........................................................................ ២

មេរៀនទី ១ : ការកំណត់គោលដៅ ,,,,,,............,,,,,,,,,,.,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ៣

មេរៀនទី ២ : គោលដៅ និង អនាគត ,,,,,,,,,,,,,,,,,,,,,,,,,,,,,....,,,,,,,,,,,,,,,,,,,,,,,,,, ១០

មេរៀនទី ៣ : ការធ្វើផែនទីកំណត់ទីតាំងមុខរបរ ,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ១៥

មេរៀនទី ៤ : ការចាប់អារម្មណ៍លើមុខរបរ និង ការស្រាវជ្រាវ ,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ១៩

មេរៀនទី ៥ : ការធ្វើសម្ភាសពីមុខរបរ ,,,,,,,,,.........................,,,,,,,,,,,,,,,,,,,,,,,,,,, ២៥

មេរៀនទី ៦ : ការធ្វើផែនការសម្រាប់អនាគតអ្នក ,,,,.......,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ២៧

មេរៀនទី ៧ : ការធ្វើសេចក្តីសម្រេចចិត្ត ,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ៣១

មេរៀនទី ៨ : អ្នកធ្វើការសម្រេចចិត្តដែលឈ្លាសវៃ ,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ៣៨

ការសង្ខេបពីខ្លឹមសារឯកសារស្តីពីអនាគតខ្ញុំ ................................................ ៤០

## អារម្ភកថា

ឯកសារ **អនាគតខ្ញុំ** មានគោលបំណងជួយអ្នកសិក្សាទាំងអស់ឱ្យទទួលបានចំណេះដឹង និង ជំនាញ ដែលអាចពង្រីកគោលគំនិត អំពីលទ្ធភាពនៃការជ្រើសរើសមុខរបរនាពេលអនាគត។ ទោះបីជាមានប្រភេទមុខរបរ ដែលផ្តល់តាមរយៈនិយោជិក ឬ មុខរបរដែលបង្កើតឡើងដោយខ្លួនឯងក៏ដោយ។ ការសិក្សាបន្ថែមទៀតពីជំនាញដែលមានស្រាប់ ពីតម្រូវការការអប់រំ ចំណេះដឹង និង ជំនាញផ្សេងៗទៀត សម្រាប់ធ្វើផែនការ ស្វែងរកការងារ និង ធ្វើការសម្រេចចិត្ត។ សព្វថ្ងៃនេះ យុវជនជាច្រើនមិនបានកំណត់ពីវិថីនៃអនាគតរបស់ពួកគេទេ ដោយការគាប់ជួនសុទ្ធសាធ គឺមិនមែនដោយការតាំងចិត្ត ដែលគេស្វែងរកពិតប្រាកដនោះទេ។ ការជួយពួកគេក្នុងការស្រាវជ្រាវ អំពីជំនាញផ្សេងៗ ការកំណត់ផែនការសកម្មភាព និង ការសម្រេចចិត្តរើសយកជំនាញអ្វីមួយនោះ ជាកត្តាជំរុញឱ្យពួកគេឆ្ពោះទៅរកជំនាញជាក់លាក់ អាចធ្វើឱ្យគេមានការជឿជាក់លើខ្លួនឯង និង មានភាពក្លាហានក្នុងការស្វែងរក មុខរបរដើម្បីកសាងអនាគតរបស់ខ្លួន។ យើងសង្ឃឹមថាយុវជននាសម័យនេះ អាចធ្វើការជ្រើសរើសមុខរបរអ្វីមួយ ដោយមានព័ត៌មានគ្រប់គ្រាន់ ដែលខ្លួនអាចទទួលយកបាន។

# ឯកសារសម្រាប់គ្រូ

## ការណែនាំអនុវត្ត

### ☑ ការរៀបចំរបស់គ្រូមុនការបង្រៀន

គ្រូត្រូវអានកិច្ចតែងការបង្រៀនប្រចាំថ្ងៃមុននឹងទៅបង្រៀន ដើម្បីធានាថាសម្ភារៈបង្រៀនដែលត្រូវការ ត្រូវបានផលិត ឬបានទទួលហើយអាចប្រើក្នុងសកម្មភាពរៀន និង បង្រៀនឱ្យស្ទាត់ជំនាញ និងមានប្រសិទ្ធភាព។

### រយៈពេលបង្រៀន

មេរៀននីមួយៗត្រូវបង្រៀនក្នុងរយៈពេល ២ម៉ោងសិក្សា (១០០ នាទី)

### សម្ភារៈ

សម្ភារៈដែលត្រូវការ មានសរសេរនៅក្នុងមេរៀននីមួយៗ។ គ្រូគួរពិនិត្យមើលលំនាំបង្រៀននៃមេរៀនមុននឹងទៅបង្រៀន ដើម្បីធានាថាសម្ភារៈទាំងអស់មានគ្រប់សព្វហើយ។ សៀវភៅសិស្សមានសារៈសំខាន់សម្រាប់សិស្ស។ ខ្លឹមសារនៅក្នុងសៀវភៅសិស្សមានសំណួរពិភាក្សា និង សកម្មភាពដែលទាក់ទងនឹងការបង្រៀន។

### លទ្ធផលសិក្សារំពឹងទុក

នៅក្នុងមេរៀននីមួយៗ មានសរសេរអំពីលទ្ធផលសិក្សារំពឹងទុក។ លទ្ធផលសិក្សាដែលបង្ហាញនៅក្នុងឯកសារនេះ គឺដើម្បីជួយគ្រូឱ្យយល់អំពីវត្ថុបំណងសំខាន់ៗសម្រាប់មេរៀននីមួយៗ និងដើម្បីឱ្យគ្រូគិតពីសកម្មភាពសិក្សាដែលគ្រូត្រូវដឹកនាំក្នុងពេលបង្រៀន។ ប្រសិនបើគ្រូចងចាំលទ្ធផលសិក្សានោះ គ្រូនឹងអាចវាយតម្លៃបានថាមេរៀនដែលខ្លួនបង្រៀននោះបានសម្រេច ឬមិនសម្រេចវត្ថុបំណង។

# ឯកសារសម្រាប់គ្រូ

## មេរៀនទី ១ : ការកំណត់គោលដៅ

🕑 **រយៈពេលបង្រៀន** ២ ម៉ោង

☑ **ការរៀបចំរបស់គ្រូមុនពេលបង្រៀន**

- បង្កើតតារាងលើក្រដាសផ្ទាំងធំដែលមានសរសេរ ធាតុ ៤+២
- សរសេរគោលដៅគំរូលើក្ដារខៀន។ ប្រសិនបើសិស្សមានសៀវភៅគេអាចមើលខ្លឹមសារនៅក្នុងសៀវភៅរបស់គេ។
- គ្រូមានកិច្ចការផ្ទះសម្រាប់ឱ្យសិស្សធ្វើ ដោយសរសេរលើក្រដាសផ្ទាំងធំរួចជាស្រេច ប្រសិនបើសិស្សមានសៀវភៅគេអាចមើលខ្លឹមសារនៅក្នុងសៀវភៅរបស់គេ។

📖 **សម្ភារៈ**

- ឯកសារណែនាំសម្រាប់គ្រូ
- សៀវភៅសិស្ស
- សម្ភារៈបង្រៀនដែលមានរៀបចំខាងលើ
- ក្ដារខៀន និង ដីស
- ក្រដាសផ្ទាំងធំ និង ហ្វឺត សម្រាប់បញ្ជីឈ្មោះសិស្ស
- កម្រងសំណួរ ខ្លឹមសារមេរៀន

✡ **លទ្ធផលសិក្សារំពឹងទុក**

ពេលរៀនមេរៀននេះចប់សិស្សនឹងអាច :

- ប្រាប់ពីអត្ថន័យនៃ ពាក្យ " គោលដៅ "។
- កំណត់គោលដៅសម្រាប់អនាគតខ្លួនដោយមានភាពប្រាកដនិយម។

## លំនាំនៃការបង្រៀន

| សកម្មភាពទី ១ : តើគោលដៅជាអ្វី? | ១៥ នាទី |
|---|---|

១. គ្រូសួរសំណួរ :

- ចូរប្រាប់និយមន័យ នៃពាក្យ "**គោលដៅ** " និង ផ្ដល់ឧទាហរណ៍
- គ្រូឱ្យសិស្សផ្ដល់និយមន័យ និង ឧទាហរណ៍
- គ្រូសួរ តើអ្នកណាអាចផ្ដល់និយមន័យផ្សេងទៀតដែលខុសប្លែកពីអ្វីដែលគេបានរៀបរាប់ដែរឬទេ?
  - ➢ ចម្លើយរំពឹងទុក
    - o ទីបញ្ចប់នៃការប្រឹងប្រែងឆ្ពោះទៅរក
    - o អ្វីដែលគេមានបំណងបំពេញឱ្យបាន ឬ ចង់សម្រេចតាមទិសដៅដែលបានកំណត់
    - o ណែនាំនូវអ្វីដែលសម្រេចបានដោយការប្រឹងប្រែងក្នុងរយៈពេលយូរនិងមានការលំបាក (ធ្វើការរយៈពេលជាច្រើនឆ្នាំដើម្បីឱ្យដល់គោលដៅ)
    - o សេចក្ដីព្យាយាមដែលនាំឆ្ពោះទៅរកគោលបំណង
    - o លទ្ធផលដែលគេរំពឹងទុកជាមុន ឬ ផែនការសកម្មភាពរបស់អ្នកដែលត្រូវឆ្ពោះទៅរក. . . ។

គ្រូសួរ ហេតុអ្វីបានជាគោលដៅមានសារៈសំខាន់សម្រាប់យើង?

២. គ្រូពន្យល់

គោលដៅជួយយើងឱ្យកំណត់ថា តើទីណាដែលយើងចង់ទៅ ឬ ចង់ក្លាយជា។ ចូរគិតពីការធ្វើដំណើរផ្សងព្រេងជុំវិញប្រទេសកម្ពុជាដោយគ្មានផែនទី ឬ ដោយគ្មានគោលដៅ។ សកម្មភាពបែបនេះ ប្រហែលជាមិនអាក្រក់ណាស់ណាទេ ប្រសិនបើយើងមិនខ្វល់ ដោយចេះតែធ្វើដំណើរត្រេចចរដោយគ្មានទិសដៅពាសពេញប្រទេសកម្ពុជាដោយគ្មានការរំពឹងទុក។ ប៉ុន្ដែ ប្រសិនបើអ្នកពិតជាចង់រកកន្លែងណាច្បាស់លាស់ ការមានទិសដៅជាក់លាក់ និងមានផែនទីច្បាស់លាស់នោះ យើងនឹងទៅដល់គោលដៅប្រកបដោយប្រសិទ្ធភាព។ គោលដៅគឺធ្វើឱ្យយើងសម្រេចគោលបំណងនេះឯង។ យើងអាចផ្សងព្រេងជាមួយអនាគតរបស់យើងដោយគ្រាន់តែឱ្យអ្វីៗដែលកើតឡើងនាំយើងឆ្ពោះទៅរកគោលដៅផ្សេងៗ ឬ អ្នកអាចកំណត់គោលដៅ ហើយស្វែងយល់ឱ្យច្បាស់ថា តើទីណាដែលអ្នកចង់ទៅ ហើយចាប់ផ្ដើមគ្រោង "**ផែនទីបង្ហាញផ្លូវ** " ដើម្បីឱ្យទៅដល់កន្លែងនោះ។

**សកម្មភាពទី ២ : ធាតុទាំង ៤ ក្នុងការសរសេរគោលដៅ** ◷ **២០ នាទី**

១. គ្រូបង្ហាញពីគោលបំណងសម្រាប់ថ្ងៃនេះ

២. គ្រូបង្ហាញពីធាតុទាំង ៤ ក្នុងការសរសេរគោលដៅ

- **អ្នកណា?** ប្រសិនបើខ្លួនយើងផ្ទាល់ ជាអ្នកសរសេរគោលដៅនោះ យើងត្រូវសរសេរថា "ខ្ញុំ"
- **អ្វី?** (តើអ្វីដែលអ្នកចង់សម្រេចឱ្យបាន? ឧ. ពាណិជ្ជករ មេធាវី អ្នកបច្ចេកទេសគ្រឿងយន្ត ...)
- **នៅទីណា?** តើនៅទីណាដែលអ្នកចង់ទៅដល់ដើម្បីសម្រេចគោលដៅនេះ?
- **ពេលណា?** តើអ្នកសង្ឃឹមថាអ្នកអាចសម្រេចគោលដៅនេះនៅពេលណា?

៣. គ្រូផ្តល់ឧទាហរណ៍ចំនួន ៥ អំពីគោលដៅដែលមានភាពច្បាស់លាស់ ដែលសិស្សត្រូវកំណត់ធាតុទាំង ៤ ដែលមាននៅក្នុងគោលដៅទាំងនោះ។

**ឧទាហរណ៍ទី ១ :** ,នៅចុងឆ្នាំនេះ ខ្ញុំនឹងបង្កើនសមត្ថភាពផ្នែកគណិតវិទ្យាឱ្យកាន់តែល្អប្រសើរ

- **អ្នកណា?** "**ខ្ញុំ**" ។
- **អ្វី?** នឹងបង្កើនសមត្ថភាពផ្នែកគណិតវិទ្យាពីចំណុចដែលស្ទើរតែមិនបានជាប់សោះកាលពីពេលកន្លងមក។
- **នៅទីណា?** ក្នុងសាលា។
- **ពេលណា?** នៅចុងឆ្នាំនេះ។

**ឧទាហរណ៍ទី២ :** ខ្ញុំនឹងចូលរៀនសាកលវិទ្យាល័យ នៅទីក្រុងភ្នំពេញ ដើម្បីសិក្សាផ្នែកជំនួញនៅឆ្នាំក្រោយមួយទៀត។

- **អ្នកណា?** "**ខ្ញុំ**" ។
- **អ្វី?** ខ្ញុំនឹងចូលរៀនសាកលវិទ្យាល័យដើម្បីសិក្សាផ្នែកជំនួញ។
- **នៅទីណា?** សាកលវិទ្យាល័យនៅទីក្រុងភ្នំពេញ។
- **ពេលណា?** ឆ្នាំក្រោយមួយទៀត។

**ឧទាហរណ៍ទី៣ :** ខ្ញុំនឹងរៀនភាសាអង់គ្លេសឱ្យមានចំណេះគ្រប់គ្រាន់ ដែលអាចធ្វើការបាននៅកន្លែងដែលមានជនបរទេសនៅទីក្រុងណាមួយ ឬ ទីប្រជុំជន ពេលខ្ញុំបញ្ចប់ការសិក្សានៅវិទ្យាល័យ។

- **អ្នកណា?** "ខ្ញុំ"
- **អ្វី?** នឹងរៀនភាសាអង់គ្លេសឱ្យមានចំណេះដឹងគ្រប់គ្រាន់ ដែលអាចធ្វើការបាននៅកន្លែងដែលមានជនបរទេស។
- **នៅទីណា?** ទីក្រុងណាមួយ ឬ ទីប្រជុំជន។

- ពេលណា? បញ្ចប់ការសិក្សានៅវិទ្យាល័យ ។

**ឧទាហរណ៍ទី៤ :** ខ្ញុំ នឹងធ្វើការងារដើម្បីសន្សំប្រាក់ទិញម៉ូតូមួយ សម្រាប់ប្រកបមុខរបរម៉ូតូឌុប នៅទីប្រជុំជន ក្នុងអំឡុង ប្រាំមួយខែខាងមុខ ។

- **អ្នកណា?** "ខ្ញុំ" ។
- **អ្វី?** នឹងធ្វើការងារដើម្បីសន្សំប្រាក់ទិញម៉ូតូមួយ សម្រាប់ប្រកបមុខរបរម៉ូតូឌុប ។
- **នៅទីណា?** នៅទីប្រជុំជន ។
- **ពេលណា?** ក្នុងអំឡុងប្រាំមួយខែខាងមុខ ។

**ឧទាហរណ៍ទី៥ :** ឆ្នាំក្រោយខ្ញុំនឹងមានរាងកាយមាំមួនដើម្បីចូលរួមការប្រកួតរត់ពាក់កណ្តាលម៉ារ៉ាតុន នៅខេត្តសៀមរាប ។

- **អ្នកណា?** "ខ្ញុំ" ។
- **អ្វី?** នឹងមានរាងកាយមាំមួនដើម្បីចូលរួមការប្រកួតរត់ពាក់កណ្តាលម៉ារ៉ាតុន ។
- **នៅទីណា?** នៅខេត្តសៀមរាប ។
- **ពេលណា?** ឆ្នាំក្រោយ ។

| សកម្មភាពទី៣ : ការកំណត់គោលដៅជាមួយធាតុទាំង៤ | ២៥ នាទី |
|---|---|

១. នៅក្នុងថ្នាក់គ្រូដឹកនាំសិស្សបង្កើតគោលដៅងាយៗ ធ្វើគោលដៅទូទៅ ដែលមិនចំពោះអ្នកណាម្នាក់ ។

- គ្រូលើកឡើងថាជាទូទៅពាក្យ "**អ្នកណា ?**" គឺសំដៅទៅមនុស្សដែលបង្កើតគោលដៅ ( ចម្លើយគឺ ខ្ញុំ ជាអ្នកសរសេរគោលដៅ) ។
- គ្រូធ្វើការពន្យល់ : ដោយហេតុថាយើងនឹងនាំគ្នាបង្កើតគោលដៅ ដូច្នេះគោលដៅទាំងនេះវាមិនបានសំដៅជាក់លាក់អំពីអ្នកណាម្នាក់នៅក្នុងចំណោមពួកយើងនោះទេ ពីព្រោះថាយើងនឹងអនុវត្តសរសេរគោលដៅនេះជាបុគ្គល ។

២. នៅក្នុងថ្នាក់ គ្រូបង្កើតគោលដៅគំរូចំនួន ៣ ដោយប្រើធាតុទាំង៤នេះ ។ (ចំណុចដែលសំខាន់គឺចង់ឱ្យសិស្សយល់ពីរចនាសម្ព័ន្ធនៃគោលដៅជាជាងបង្ហាញពីអារម្មណ៍របស់គេចំពោះគោលដៅទាំងនោះ) ។

- គ្រូឱ្យសិស្សម្នាក់ផ្តល់គំនិតទាក់ទងនឹងធាតុ "**អ្នកណា**" នៅក្នុងខ្លឹមសារនៃគោលដៅ ។
- គ្រូឱ្យសិស្សម្នាក់ផ្តល់គំនិតទាក់ទងនឹងធាតុ "**អ្វី**" នៅក្នុងខ្លឹមសារនៃគោលដៅ ។
- គ្រូឱ្យសិស្សម្នាក់ផ្តល់គំនិតទាក់ទងនឹងធាតុ "**នៅទីណា**" នៅក្នុងខ្លឹមសារនៃគោលដៅ ។
- បន្ទាប់មកគ្រូឱ្យសិស្សម្នាក់ផ្តល់គំនិតទាក់ទងនឹងធាតុ "**ពេលណា**" នៅក្នុងខ្លឹមសារនៃគោលដៅ ។

៣. គ្រូឱ្យសិស្សធ្វើការជាដៃគូ ដើម្បីកំណត់គោលដៅចំនួនពីរដែលពួកគេមាន :

- គោលដៅនីមួយៗត្រូវមានធាតុទាំង៤
- សិស្សត្រូវធ្វើការកត់ត្រាពីហេតុដែលធ្វើឱ្យគោលដៅទាំងនេះមានសារៈសំខាន់ ឬ មានអត្ថន័យធំធេងសម្រាប់ពួកគេ។

៤. គ្រូឱ្យសិស្សអង្គុយជាក្រុម (១ក្រុមមានគ្នា៤នាក់) ហើយធ្វើការផ្លាស់ប្តូរគោលដៅដែល គេបានសរសេរ និង ពិនិត្យធាតុទាំង៤ ដើម្បីធ្វើការកែតម្រូវប្រសិនបើចាំបាច់។

៥. គ្រូឱ្យសិស្ស ២ ឬ ៣ គូឡើងបង្ហាញពីគោលដៅរបស់គេ ហើយឱ្យសិស្សទាំងអស់ជាអ្នក កំណត់ធាតុទាំង ៤។

| សកម្មភាពទី៤ : ធាតុទាំង២ ក្នុងការធ្វើផែនការដើម្បីសម្រេចគោលដៅ | ១០ នាទី |
|---|---|

១. គ្រូបង្ហាញ ធាតុទាំង២ ក្នុងការធ្វើផែនការគោលដៅដោយធ្វើការពន្យល់ដូចខាងក្រោម :
ការសរសេរពីខ្លឹមសារគោលដៅជាក់លាក់មួយអាចជាការងាយស្រួល។ ផ្នែកដែលលំបាក និងត្រូវជំនះខ្លាំង គឺការធ្វើផែនការយ៉ាងណាដើម្បីឱ្យឈានទៅដល់គោលដៅ។ ម្យ៉ាងទៀត នៅពេលយើងធ្វើកិច្ចការនេះគឺយើង ត្រូវផ្តោតការយកចិត្តទុកដាក់ និង មានគោលបំណងជាក់លាក់ ដោយអនុលោមទៅតាមផែនការរបស់យើង។ ទោះជាយ៉ាងណាក៏ដោយក៏ផ្លូវដែលយើងត្រូវដើរនៅតែមានការកែសម្រួលខ្លះៗព្រោះវាអាស្រ័យទៅតាម ការវិវត្ត ធនធាន ស្ថានភាព និង ព្រឹត្តិការណ៍។

២. គ្រូបង្ហាញពីធាតុ៤ **+២** សម្រាប់ធ្វើផែនការដើម្បីសំរេចគោលដៅ។

- **៤+១ "ធ្វើដូចម្តេច?"** តើអ្នកអាចសម្រេចគោលដៅបានយ៉ាងដូចម្តេច?
    - **សកម្មភាព :** តើមានសកម្មភាពអ្វីខ្លះដែលត្រូវការចាំបាច់ដើម្បីឈានដល់គោលដៅរបស់អ្នក?
    - **សេចក្តីត្រូវការ :** ដើម្បីសម្រេចគោលដៅនេះ តើអ្នកនឹងត្រូវការអ្វី (ការអប់រំ បទពិសោធន៍ ធនធាន បណ្តាញគាំទ្រ)
- ៤+២ **"ភាពអាចធ្វើបាន"** តើគោលដៅនេះមានភាពប្រាកដជាក់ស្តែង និងអាចសម្រេចទៅបានដែរឬទេ?

# ឯកសារសម្រាប់គ្រូ

| សកម្មភាពទី៥ : ការសរសេរ " ធ្វើដូចម្ដេច" ក្នុងការធ្វើផែនការគោលដៅ | ◷ ៣០ នាទី |
|---|---|

១. ជាដំបូងគ្រូណែនាំពាក្យ " **ធ្វើដូចម្ដេច** " ?

២. គ្រូអាន ឧទាហរណ៍អំពីគោលដៅឡើងវិញ :

នៅចុងឆ្នាំនេះ ខ្ញុំនឹងបង្កើនសមត្ថភាពផ្នែកគណិតវិទ្យាឱ្យកាន់តែល្អប្រសើរ ។

៣. ដោយប្រើគោលដៅនេះជាឧទាហរណ៍ ចូរពិភាក្សាអំពី " **ធ្វើដូចម្ដេច** " ដើម្បីធ្វើឱ្យគោលដៅនេះអាចសម្រេចទៅបាន ។

- ចម្លើយរំពឹងទុក : សិក្សាឱ្យច្រើនជាងមុន មានគ្រូបង្រៀនបន្ថែម ត្រូវសួរគ្រូឱ្យបានច្រើន សិក្សាបន្ថែមជាក្រុម ជាមួយមិត្តភក្តិ ចំណាយពេលធ្វើកិច្ចការសាលានៅផ្ទះឱ្យបានច្រើន និងធ្វើលំហាត់បន្ថែម ។

៤. គ្រូសួរទៅសិស្ស

- តើអ្នកអាចគិតពីជំហាន ឬ សកម្មភាពផ្សេងទៀតដែលគួរបន្ថែម និងប្រើប្រាស់ជាមធ្យោបាយដើម្បីធ្វើឱ្យសម្រេចគោលដៅដែរឬទេ?
  - ចម្លើយរំពឹងទុក : បែងចែកម៉ោងជាក់លាក់ក្នុងសប្តាហ៍សម្រាប់ការសិក្សាជាក្រុម ការសិក្សាគ្រូមួយសិស្សមួយ និងសកម្មភាពសិក្សាផ្សេងទៀត ។ ត្រូវគោរពពេលវេលាដែលបានបែងចែក យកចិត្តទុកដាក់ខ្លាំងនៅក្នុងថ្នាក់ សួរគ្រូប្រសិនបើយើងមិនទាន់យល់ច្បាស់ ។
- តើអ្នកអាចគិតពីសេចក្តីត្រូវការជាក់លាក់ដែលអ្នកចង់យកមកអនុវត្តសម្រាប់ជំហាន និង សកម្មភាពទាំងនេះឬទេ?
  - ចម្លើយរំពឹងទុក : ប្រាក់សម្រាប់សិក្សាបន្ថែម បន្ថយពេលវេលាសម្រាប់ធ្វើការងារក្នុងផ្ទះដើម្បីរៀនបន្ថែមទៀត ត្រូវការម៉ាស៊ីនគិតលេខសម្រាប់ជួយផ្ទៀងផ្ទាត់ចម្លើយ ។

៥. គ្រូពន្យល់

ចម្លើយរំពឹងទុកមានជាច្រើនទាក់ទងទៅនឹងជំហាន និង សេចក្តីត្រូវការ ។ ចម្លើយទាំងនោះវាអាស្រ័យទៅលើចរិតលក្ខណៈបុគ្គលម្នាក់ៗ ធនធាន និងកត្តាផ្សេងៗ ។ ដូច្នេះវាមិនអាចមានចម្លើយត្រឹមត្រូវតែមួយនោះទេ ។

៦. គ្រូនាំសិស្សអនុវត្ត

- គ្រូបែងចែកសិស្សជាក្រុម ( មួយក្រុមមានសិស្ស ៥ នាក់)

- គ្រូឱ្យក្រុមសិស្សធ្វើកិច្ចការអនុវត្ត លើឧទាហរណ៍ទី ២,៣,៤ ឬ ៥ដែលមានក្នុងសកម្មភាពទី២ ។
- សិស្សធ្វើការកំណត់ " **ធ្វើដូចម្តេច** " សម្រាប់កិច្ចការដែលគ្រូបានដាក់ឱ្យ ។

៧. គ្រូឱ្យក្រុមសិស្សពន្យល់ពីចម្លើយមួយចំនួនចំពោះឃ្លា " **ធ្វើដូចម្តេច?** " សម្រាប់ឧទាហរណ៍ទី ១ ។ គ្រូបំផុសគំនិតដើម្បីឱ្យសិស្ស ផ្តល់ចម្លើយឱ្យបានច្រើន ហើយរាល់ចម្លើយទាំងអស់ សុទ្ធតែត្រូវ ។

៨. គ្រូឱ្យក្រុមសិស្សពន្យល់ពីចម្លើយមួយចំនួនចំពោះឃ្លា " **ធ្វើដូចម្តេច?** " សម្រាប់ឧទាហរណ៍ទី ២-៥ ។ គ្រូបំផុសគំនិតដើម្បីឱ្យសិស្សផ្តល់ចម្លើយឱ្យបានច្រើន ហើយរាល់ចម្លើយទាំងអស់សុទ្ធតែត្រូវ ។

**កិច្ចការនៅផ្ទះ**

១. គ្រូឱ្យសិស្សធ្វើកិច្ចការផ្ទះ
- សរសេរពីគោលដៅរបស់ខ្លួនចំនួន ២ ។
- ការសរសេរត្រូវគ្របដណ្តប់ឱ្យគ្រប់ធាតុទាំង ៥ នៃការសរសេរគោលដៅ ដែលទើបនឹងរៀនរួចនៅថ្ងៃនេះ ធាតុ ៤ សម្រាប់ខ្លឹមសារនៃគោលដៅ និង " **ធ្វើដូចម្តេច** " សម្រាប់ធ្វើផែនការដើម្បីធ្វើឱ្យសម្រេចគោលដៅនោះ ។
- គោលដៅទាំង ២ គួរតែជារបស់ដែលគេសង្ឃឹមថាអាចសម្រេចបាននៅខែក្រោយ ឬក៏ឆ្នាំក្រោយ ។
- គ្រូឱ្យសិស្សគិតពីគោលដៅ ដែលគេមានសម្រាប់ទិដ្ឋភាពផ្សេងៗនៃជីវភាពរស់នៅរបស់ពួកគេ ដូចជា ការអប់រំ អាជីព គ្រួសារ សង្គម ចំណង់ចំណូលចិត្ត ការអភិវឌ្ឍបុគ្គល ឬ អ្វីផ្សេងទៀត ។
- សិស្សត្រូវផ្តល់កិច្ចការនេះនៅថ្ងៃសិក្សាបន្ទាប់ ។
- សិស្សត្រូវរៀបចំធ្វើការបង្ហាញដោយសង្ខេប (៥នាទី) សម្រាប់គោលដៅមួយ នៅថ្ងៃសិក្សាបន្ទាប់ ។

## មេរៀនទី២ : គោលដៅ និង អនាគតអ្នក

🕑 **រយៈពេល** ២ ម៉ោង

☑ **ការរៀបចំរបស់គ្រូមុនបង្រៀន**

- សំណួររំលឹកមេរៀនចាស់ (មេរៀនទី១)
- គ្រូពិនិត្យមើលសៀវភៅសិស្ស ដើម្បីចង់ដឹងព័ត៌មាន និង សំណួរដែលសិស្សត្រូវធ្វើ ។
- ក្រដាសផ្ទាំងធំដែលមានសរសេរធាតុ ៤+២ ។ ប្រសិនបើសិស្សមានសៀវភៅគេអាច មើលខ្លឹមសារទាំងនេះ នៅក្នុងសៀវភៅរបស់គេ ។
- សរសេរគោលដៅគំរូចំនួន ៣ លើក្ដារខៀន ។ ប្រសិនបើសិស្សមានសៀវភៅគេអាចមើលខ្លឹមសារទាំងនេះនៅក្នុងសៀវភៅរបស់គេ ។
- គ្រូមានកិច្ចការផ្ទះសម្រាប់ឱ្យសិស្សធ្វើ ដោយសរសេរលើក្រដាសផ្ទាំងធំ ។ ប្រសិនបើសិស្សមានសៀវភៅគេអាចមើលខ្លឹមសារទាំងនេះនៅក្នុងសៀវភៅរបស់គេ ។

📖 **សម្ភារៈ**

- ឯកសារណែនាំសម្រាប់គ្រូ
- សៀវភៅសិស្ស
- សម្ភារៈបង្រៀនដែលមានរៀបចំខាងលើ
- ក្ដារខៀន និង ដីស
- ក្រដាសផ្ទាំងធំ និង ហ្វឺត បញ្ជីឈ្មោះសិស្ស
- កម្រងសំណួរ ខ្លឹមសារមេរៀន

☼ **លទ្ធផលសិក្សារំពឹងទុក**

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច :

- កំណត់អត្ថន័យ និង យល់ពីគោលដៅ
- កំណត់គោលដៅសម្រាប់អនាគតដែលមានទាំងភាពជាក់លាក់និងអាចសម្រេចបាន
- ទទួលបានបទពិសោធន៍ និងយល់ពីបញ្ហាប្រឈមក្នុងការកំណត់ និង ការធ្វើឱ្យសម្រេចគោលដៅ ។

**លំនាំនៃការបង្រៀន**

| សកម្មភាពទី ១ : ការកំណត់គោលដៅដែលអាចសម្រេចបាន | ១៥ នាទី |
|---|---|

១. គ្រូពន្យល់សិស្ស

នៅពេលបង្កើតគោលដៅ ចូរយើងចាំឱ្យច្បាស់ថា យើងមិនត្រូវលើកឡើងនូវការស្រមើស្រមៃដែលមិនអាចធ្វើបាន ឬជាគំនិតរវើរវាយនោះទេ។ យើងលើកឡើងពីគោលដៅដែលអាចកើតមានប្រាកដដែលជាពន្លឺនៃក្តីសង្ឃឹម ។ យើងចង់និយាយអំពីគោលដៅដែលបុគ្គលម្នាក់ៗមានលទ្ធភាព សេចក្តីព្យាយាម និងការតាំងចិត្តដើម្បីធ្វើបានសម្រេច។ ប្រសិនបើអ្នកគិតថានឹងត្រូវឆ្នោត ឬ មានភ័ព្វសំណាងដែលហួសពីការត្រួតត្រារបស់អ្នកនោះ វាមិនមែនជាគោលដៅទេ។ វាគ្រាន់តែជាក្តីសុបិន និងភាពរវើរវាយតែប៉ុណ្ណោះ។

មនុស្សទាំងអស់មិនមែនសុទ្ធតែជឿជាក់ថាខ្លួនអាចសម្រេចគោលដៅបាននោះទេ។ សារៈសំខាន់ពិតប្រាកដគឺអ្នកត្រូវជឿជាក់ថាអ្នកអាចសម្រេចគោលដៅរបស់អ្នកបាន។ មនុស្សជាច្រើនបានសម្រេចគោលដៅដែលគ្មាននរណាម្នាក់ស្មានត្រូវ។ ប្រសិនបើអ្នកកំណត់គោលដៅ ហើយមានការយល់ដឹងផ្ទាល់ខ្លួន មានទេពកោសល្យផ្ទាល់ខ្លួន មានការសម្រេចចិត្ត និងមានចំណង់ធ្វើឱ្យសម្រេចនូវរាល់បញ្ហាប្រឈមទាំងអស់នោះអ្នកមិនគួរឱ្យជំនឿផ្សេងទៀតមកផ្លាស់ប្តូរសេចក្តីជឿជាក់របស់អ្នកឡើយ។

២. គ្រូឱ្យសិស្សទាំងអស់ផ្តល់ឧទាហរណ៍អំពីគោលដៅគំរូដំបូង។

- ពិនិត្យមើលឧទាហរណ៍នេះជាថ្មីម្តងទៀត នៅចុងឆ្នាំនេះ ខ្ញុំនឹងបង្កើនសមត្ថភាពផ្នែកគណិតវិទ្យាឱ្យកាន់តែល្អប្រសើរ។
- តាមយោបល់របស់អ្នក តើអ្នកជឿថាគោលដៅនេះមានភាពប្រាកដប្រជា និងអាចសម្រេចបានដែរឬទេ?
- ចូរពន្យល់ថា ហេតុអ្វីបានជាអ្នកគិតដូចនេះ?
  - ចម្លើយរំពឹងទុក : ចាស/បាទ គោលដៅនេះអាចសម្រេចបាន ប្រសិនបើយើងមានឆន្ទៈក្នុងការកំណត់ និងធ្វើការងារខ្លាំង ។ ប្រសិនបើយើងមានប្រាក់បន្ថែមទៀត វាអាចឱ្យគេទទួលបានការបង្រៀនបំប៉នបន្ថែម។ យើងក៏អាចរកសិស្សផ្សេង ឬ បងប្អូនដែលមានការយល់ដឹងមុខវិជ្ជាគណិតវិទ្យាមកជួយពន្យល់ ។
- តើព័ត៌មានអ្វីខ្លះដែលមានសារៈសំខាន់ក្នុងការនាំឱ្យយើងអាចឆ្លើយសំណួរទាំងនេះបាន?

- ចម្លើយរំពឹងទុក
    - ត្រូវស្គាល់ពីគោលដៅ ត្រូវមានធាតុទាំងបួននៅក្នុងគោលដៅព្រមទាំងត្រូវមានគំនិតនៃសកម្មភាពដែលអាចធ្វើទៅបាន ដើម្បីសម្រេចនូវគោលដៅនោះ ។
    - ការខ្វះផែនការនៃជំហាននីមួយៗវាក៏អាចធ្វើឱ្យគោលដៅមិនប្រាកដប្រជា ឬ មិនអាចសម្រេចបានផងដែរ ។

៣. ឥឡូវនេះចូរមើលឧទាហរណ៍ ដែលអ្នកបានធ្វើនៅក្នុងក្រុមតូច បន្ទាប់មកគ្រូត្រឡប់ទៅសកម្មភាព ៤+២ : ***ភាពអាចធ្វើបាន*** ។

- ***"ភាពអាចធ្វើបាន"*** សំណួរចុងក្រោយដែលត្រូវសួរខ្លួនយើងគឺ : តើគោលដៅនេះមានភាពប្រាកដប្រជា និងអាចសម្រេចបានដែរឬទេ?

៤. គ្រូលើកជាសំណួរដល់សិស្ស

- ចូរមើលគោលដៅដែលគ្រូបានឱ្យអ្នកបង្កើតនៅក្នុងក្រុមតូចកាលពីមេរៀនលើកមុន ។
- ចម្លើយ : "តើគោលដៅនេះអាចសម្រេចទៅបាន ឬ មិនបាន "?
- គ្រូឱ្យសិស្ស ដែលបានឆ្លើយថា "**បាន** " និង សិស្សដែលឆ្លើយថា "**មិនបាន**" លើកជាឧទាហរណ៍ ។
- គ្រូឱ្យសិស្សធ្វើការពន្យល់ដោយសង្ខេប ពីចម្លើយរបស់ពួកគេ ។

៥. គ្រូសរសេរឃ្លាចំនួន ២ នៅលើក្តារខៀន ***"អាចសម្រេចបាន"*** និង ***"នឹងសម្រេចបាន"*** ហើយសួរថា :

- តើឃ្លាទាំង ២ នេះដូចគ្នាដែរឬទេ? ចូរពន្យល់ពីចម្លើយរបស់អ្នក ។
    - ចម្លើយរំពឹងទុក :
        - គោលដៅអាចសម្រេចបាន ប៉ុន្តែមានកត្តាជាច្រើនដែលធ្វើឱ្យយើងអាចសម្រេចគោលដៅនោះបានឬ មិនបាន?
        - កត្តាខ្លះយើងអាចត្រួតត្រាលើវាបានដូចជា តើយើងត្រូវសិក្សាច្រើនបែបណា? តើយើងត្រូវធ្វើការច្រើនបែបណា ដើម្បីកែលំអការអនុវត្តរបស់យើង ។
        - កត្តាខ្លះទៀតយើងមិនអាចត្រួតត្រាលើវាបាន (តាមរយៈនេះមិនមានន័យថាវាធ្វើ ឱ្យគោលដៅរបស់យើងមិនអាចសម្រេចទៅបាននោះទេ) ដូចជាការទទួលហិរញ្ញវត្ថុធនធាន ដើម្បីគាំទ្រសេចក្តីត្រូវការ របាំងសង្គម ឬ របាំងនយោបាយ ការអប់រំដែលត្រូវការជាមុន ឬ បទពិសោធន៍ដែលមិនមាននៅក្នុងប្រទេស និងក្នុងតំបន់ ។

**សកម្មភាពទី២ : ការពិភាក្សាពីគោលដៅរបស់យើងម្នាក់ៗ** ⌚ ៤៥ នាទី

១. គ្រូបែងចែកសិស្សជាក្រុម (៦នាក់ក្នុង១ក្រុម) ហើយផ្ដល់ការណែនាំ :

- សមាជិកក្នុងក្រុមនីមួយៗ ត្រូវបង្ហាញគោលដៅ ១ ក្នុងចំណោមគោលដៅទាំង២ ដែលគេបានធ្វើសម្រាប់កិច្ចការផ្ទះ (សិស្សម្នាក់ៗមានពេល ៥នាទី) ។
- នៅពេលតំណាងក្រុមឡើងបង្ហាញ សិស្សផ្សេងទៀតត្រូវស្ដាប់ហើយបន្ថែមគំនិតរបស់ខ្លួនទៅតំណាងក្រុមសិស្សនោះព្រមទាំងតាមដានថា:
  - តើមានធាតុទាំង ៤ នៅក្នុងគោលដៅនេះឬទេ?
  - តើ " **ធ្វើដូចម្ដេច?** " ត្រូវបានគេបញ្ជាក់ច្បាស់ជាមួយនឹងជំហាន និងសេចក្ដីត្រូវការដែរឬទេ?
  - តើមានសេចក្ដីត្រូវការ និងជំហានផ្សេងទៀតគួរបន្ថែមដែរ ឬទេ?
  - តើពួកគេគិតថាគោលដៅនេះអាចសម្រេចទៅបានដែរឬទេ? បើបានតើហេតុអ្វី? បើមិនបាន តើហេតុអ្វី?
- ក្រុមនីមួយៗ រើសគោលដៅរួមមួយ ដើម្បីបង្ហាញទៅសិស្សក្នុងថ្នាក់ទាំងអស់ :
  - ក្នុងក្រុមអាចមានសមាជិកច្រើនជួយបង្ហាញពីលំនាំនៃការបង្កើតគោលដៅ ៤+២ គឺមិនមែនបុគ្គលដែលមានគោលដៅទើបត្រូវបានគេលើកយកមកបង្ហាញនោះទេ ។
  - សមាជិកក្រុមគួរបញ្ជាក់ថា ហេតុអ្វីបានជាពួកគេជ្រើសយកគោលដៅមួយនេះក្នុងចំណោមគោលដៅទាំងនោះ ។

**សកម្មភាពទី៣ : ការបង្ហាញពីគោលដៅនៅក្នុងថ្នាក់** ⌚ ៣០ នាទី

១. ក្រុមតូចនីមួយៗ បង្ហាញពីគោលដៅរបស់ក្រុមខ្លួន ដែលបានជ្រើសរើស :

- សមាជិកក្រុមអាចបង្ហាញជារួម ឬ បង្ហាញតាមផ្នែកនៃលំនាំបង្កើតគោលដៅ ៤ +២ ។
- សមាជិកក្រុមកំណត់មូលហេតុដែលពួកគេជ្រើសយកគោលដៅនេះមកបង្ហាញ ។

២. ក្រោយពីការបង្ហាញគោលដៅគំរូរបស់ក្រុមតូចនីមួយៗរួច គ្រូសួរសិស្សថា:

- តើគោលដៅពួកគេមានធាតុទាំង ៤ដែរឬទេ?
- តើសេចក្ដីត្រូវការ និងជំហាន ដើម្បីនាំទៅដល់គោលដៅនោះត្រូវបានបញ្ជាក់ច្បាស់លាស់ដែរឬទេ?
- ឱ្យសិស្សផ្ដល់ជាអនុសាសន៍ ឬលើកជាសំនួរអំពីពាក្យ "**ធ្វើយ៉ាងណា?**" (សេចក្ដីត្រូវការ និង ជំហាន)
- តើអ្នកគិតថាគោលដៅនេះអាចសម្រេចបានឬទេ? សូមពន្យល់?

**សកម្មភាពទី ៤ : ការលំបាកក្នុងការកំណត់គោលដៅ** ◷ **១០ នាទី**

១. គ្រូសួរសំណួរ

- តើមានការលំបាកអ្វីខ្លះដែលអ្នកបានជួបប្រទះក្នុងការសរសេរគោលដៅ និង ការធ្វើផែនការគោលដៅ?
- តើអ្នកបានរៀនសូត្រអ្វីខ្លះដែលមានសារប្រយោជន៍សម្រាប់អ្នក និងជួយជាប្រយោជន៍សម្រាប់អនាគតរបស់អ្នក?

## មេរៀនទី៣ ៖ ការធ្វើផែនទីកំណត់ទីតាំងមុខរបរ

**រយៈពេលបង្រៀន** ២ ម៉ោង

☑ **ការរៀបចំរបស់គ្រូមុនការបង្រៀន**

- សំណួររំលឹកមេរៀន
- គ្រូពិនិត្យមើលសៀវភៅសិស្ស ដើម្បីចង់ដឹងពីព័ត៌មាន និង សំណួរដែលសិស្សត្រូវធ្វើ ។
- ក្រដាសផ្ទាំងធំសរសេរប្រភេទកន្លែងធ្វើការងារទាំង៤ប្រភេទ សម្រាប់ ល្បែងឈ្មោះមុខរបរ ដែលមាននៅក្នុងបញ្ជីក្នុងសកម្មភាពទី២ (ក)" **សហគមន៍** " (ខ)" **ស្រុក ឬ ខេត្ត** " (គ) ប្រទេសកម្ពុជា (ឃ)" **ពិភពលោក** " សម្រាប់សកម្មភាពទី ៣។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលខ្លឹមសារទាំងនេះនៅក្នុងសៀវភៅរបស់គេ។
- គូសបណ្ណពិន្ទុលើក្រដាសផ្ទាំងធំសម្រាប់សកម្មភាពទី៤។ ប្រសិនបើសិស្សមានសៀវភៅគេអាចមើលខ្លឹមសារទាំងនេះនៅក្នុងសៀវភៅរបស់គេ។
- គូសរចនាសម្ព័ន្ធផ្លូវថ្នល់ នៃសហគមន៍ ឬ ទីប្រជុំជនលើក្រដាសផ្ទាំងធំ។
- រៀបចំត្រៀមសម្ភារៈដែលត្រូវបង្រៀន។

**សម្ភារៈ**

- ឯកសារណែនាំគ្រូ
- ក្រដាសផ្ទាំងធំ និង ហ្វឺត
- កម្រងសំណួរ ខ្លឹមសារមេរៀន
- រង្វាន់តិចតួចសម្រាប់សិស្ស២០ភាគរយ
- សម្ភារៈបង្រៀន ដែលបានរៀបចំខាងលើ។

☼ **លទ្ធផលសិក្សារំពឹងទុក**

ពេលរៀនមេរៀននេះចប់សិស្សនឹងអាច

- ប្រាប់ពី មុខរបរមួយចំនួនដែលមាននៅក្នុងសហគមន៍ ស្រុក ខេត្ត ប្រទេសរបស់ពួកគេ និងប្រទេសផ្សេងៗ
- កំណត់វិធីមួយចំនួនដើម្បីស្វែងរកមុខរបរ
- បង្ហាញពីសារៈសំខាន់នៃព័ត៌មានក្នុងការជ្រើសរើសមុខរបរ។

**លំនាំនៃការបង្រៀន**

| សកម្មភាពទី ១ : ការណែនាំពីជម្រើសមុខរបរ | ⌚ ៥ នាទី |
|---|---|

១. គ្រូពន្យល់

ការគិតពីមុខរបរដែលមាននៅក្នុងសហគមន៍វាមានសារៈសំខាន់ ពីព្រោះវាឱ្យយើងដឹងពីសក្ដានុពលនៃមុខរបរដែលយើងចង់ស្វែងយល់ ។ ប្រសិនបើយើងមិនបានគិតពីមុខរបរជម្រើសផ្សេងៗនោះទេ យើងនឹងជួបបញ្ហាក្នុងការសម្រេចចិត្តជ្រើសរើសមុខរបរទាំងនោះ ។

២. គ្រូពន្យល់ពីគោលបំណងនៃការសិក្សាសម្រាប់ថ្ងៃនេះ

| សកម្មភាពទី២ : ល្បែងកំណត់ឈ្មោះមុខរបរ | ⌚ ៣៥នាទី |
|---|---|

១. គ្រូបែងចែកសិស្សជា៥ក្រុម

២.គ្រូផ្ដល់ក្រដាសផ្ទាំងធំ និង ហ្វឺត ឬ សិស្សអាចប្រើក្រដាសផ្ទាល់ខ្លួនរបស់ក្រុមនីមួយៗ ។

៣. គ្រូពន្យល់ពីរបៀបលេងល្បែង

- ពួកយើងត្រូវគិតពីមុខរបរមួយចំនួនសម្រាប់ធ្វើការពិចារណា ។ មុខរបរទាំងនោះអាចជាមុខរបរផ្លូវការ ឬ មុខរបរផ្ទាល់ខ្លួន ។
- សិស្សត្រូវចម្លងប្រភេទមុខរបរទាំង៤ប្រភេទ ដាក់លើក្រដាសផ្ទាំងធំរបស់ខ្លួនដោយធ្វើការកត់ត្រាដូចខាងក្រោម :

    ក. មុខរបរដែលមានក្នុងសហគមន៍និង នៅក្រៅសហគមន៍ ។

    ខ. មុខរបរដែលមិនមានក្នុងសហគមន៍ ប៉ុន្តែមាននៅក្នុងស្រុក ឬ ខេត្ត និងអាចមាននៅស្រុក ឬ ខេត្តផ្សេង ។

    គ. មុខរបរដែលមិនមាននៅក្នុងសហគមន៍ ស្រុក ឬ ខេត្ត ប៉ុន្តែមានក្នុងប្រទេសកម្ពុជា និង អាចមាននៅក្នុងប្រទេសផ្សេង ។

    ឃ. មុខរបរដែលមិនមាននៅគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា ប៉ុន្តែមានក្នុងពិភពលោក ។

- ចូរធ្វើការជាក្រុម ដើម្បីបង្កើតបញ្ជីមុខរបរឱ្យបានច្រើនតាមដែលអ្នកអាចគិតឃើញ ។

៤. គ្រូពន្យល់សិស្សពីអ្វីដែលក្រុមនឹងត្រូវធ្វើ

☞ អ្នកមានពេល១៥នាទីក្នុងការស្រង់បញ្ជីមុខរបរ ដែលក្រុមរបស់អ្នករកឃើញដាក់តាមប្រភេទទាំង៤ ។

- សរសេរចម្លើយលើតារាងសម្រាប់ប្រភេទមុខរបរនីមួយៗ( ក,ខ,គ,ឃ)ដែលមាននៅលើក្រដាសផ្ទាំងធំ
- យើងនឹងដាក់ពិន្ទុសម្រាប់ចម្លើយរបស់អ្នក ដើម្បីឱ្យដឹងថាតើក្រុមណាទទួលបានជ័យជំនះ។ គ្រប់ប្រភេទទាំងអស់នឹងត្រូវដាក់ពិន្ទុខុសៗគ្នា។ ដូចនេះអ្នកមិនត្រូវទុកឱ្យប្រអប់ព័ត៌មានក្នុងប្រភេទមុខរបរនីមួយៗនៅទំនេរចោលនោះឡើយ។
    - o ប្រភេទមុខរបរណាដែលរកបានចម្លើយច្រើនជាងគេបំផុត នឹងត្រូវដាក់ពិន្ទុច្រើនជាងគេ។
    - o ប្រភេទមុខរបរណាដែលរកបានចម្លើយតិចជាងគេបំផុត នឹងត្រូវដាក់ពិន្ទុតិចជាងគេ។

៥. ក្រោយពេល១៥នាទី ក្រុមនីមួយៗមានក្រដាសផ្ទាំងធំដែលបានកត់ត្រាចម្លើយ។

- គ្រប់ក្រុមត្រូវបិទក្រដាសផ្ទាំងធំដែលមានកត់ត្រាចម្លើយ។
- តំណាងក្រុមនីមួយៗឡើងអានបញ្ជីមុខរបរ។
- នៅពេលអានចប់អស់ហើយ សិស្សទាំងអស់ត្រូវធ្វើការពិភាក្សា ថាតើបញ្ជីទាំងនោះត្រឹមត្រូវដែរឬទេ។
- ដាក់សញ្ញា "X" នៅលើចម្លើយដែលមិនត្រឹមត្រូវ។

**សកម្មភាពទី ៣ : ការពង្រីកការយល់ដឹងអំពីមុខរបរ** ◷ **១៥ នាទី**

១. គ្រូពន្យល់

នៅលើពិភពលោកយើងនេះមានមុខរបរច្រើនណាស់។ នៅក្នុងប្រទេសកម្ពុជាក៏មានមុខរបរច្រើនដែរ។ មុខរបរមួយចំនួនគេមិនទាន់យល់ច្បាស់ ព្រោះគេមិនទាន់ទទួលបទពិសោធន៍ពីអ្នកមានវិជ្ជាជីវៈ ឬជាមួយនឹងមុខទំនិញ ឬការផ្ដល់សេវាកម្មនោះ។

២. គ្រូសួរសំណួរ

- តើអ្នកដឹងពីមុខរបរដែលក្រុមរបស់អ្នកបានសរសេររៀបរាប់លើតារាងល្បែងមុខរបរដោយរបៀបណា?
    - ➢ ចម្លើយរំពឹងទុក
        - o សមាជិកគ្រួសារ មិត្តភក្តិ ដែលធ្វើការលើមុខរបរទាំងនោះ។
        - o ស្គាល់តាមរយៈបទពិសោធន៍ ការប្រើប្រាស់មុខរបរទាំងនោះ ឬ ធ្វើដំណើរឆ្លងកាត់ការិយាល័យមុខរបរទាំងនោះ។
        - o ស្គាល់តាមរយៈប្រពន្ធ័ផ្សព្វផ្សាយ កាសែត ទូរទស្សន៍ វិទ្យុ និង ការផ្សាយពាណិជ្ជកម្ម។
        - o ស្គាល់តាមរយៈអ៊ិនធឺណិត។
        - o សមាជិកគ្រួសារ មិត្តភក្តិពិភាក្សា ឬ ពន្យល់ពីមុខរបរទាំងនោះ។

- តើអ្នកគិតថាធ្វើយ៉ាងណាដើម្បីស្វែងយល់បន្ថែមទៀតពីប្រភេទផ្សេងៗនៃការងារ ឬ មុខរបរទាំងនោះ?
  - ចម្លើយរំពឹងទុក
    - ពិនិត្យមើលក្នុងសហគមន៍ ស្រុក ឬ ខេត្ត ។
    - ចូលទៅក្នុងមជ្ឈដ្ឋានមុខរបរ ដើម្បីសួរព័ត៌មាន ។
    - អានកាសែតផ្សេងៗ ដើម្បីឱ្យដឹងថាតើនៅលើពិភពលោកមានអ្វីកើតឡើង និងគេកំពុងធ្វើអ្វី ។
    - រកមើលមនុស្សនៅក្នុងសហគមន៍ដែលធ្វើដំណើរច្រើនទីកន្លែងក្នុងប្រទេស និង ក្រៅប្រទេស ដើម្បីសួរពីប្រភេទការងារដែលពួកគេបានធ្វើ ។
    - រកជនបរទេសដែលធ្វើការក្នុងអង្គការ ឬ អ្នកស្ម័គ្រចិត្តដើម្បីឱ្យពួកគាត់និយាយពីមុខរបរផ្សេងៗ ដែលគេធ្លាប់ធ្វើ ។
    - អញ្ជើញបុគ្គលិកសុខភាព រដ្ឋបាល កសិកម្ម ភ្នាក់ងារសហគមន៍ មន្ត្រីសហគមន៍ គ្រូ មកសាលា ដើម្បីធ្វើបទបង្ហាញ ឬ ទៅធ្វើសម្ភាសពួកគាត់ ។

| សកម្មភាពទី៤ : ការធ្វើផែនទីកំណត់ប្រភេទមុខរបរនៅក្នុងសហគមន៍ | ២៥ នាទី |
|---|---|

១. គ្រូបិទក្រដាសផ្ទាំងធំដែលមានគូរផែនទីផ្លូវនៅក្នុងសហគមន៍ ឬ ទីប្រជុំជនរួចឱ្យសិស្សចម្លងចូលទៅក្នុងសៀវភៅកត់ត្រារបស់ពួកគេ ។

២. បន្ទាប់មកគ្រូបែងចែកសិស្សជាក្រុមតូចរួចធ្វើការណែនាំដូចខាងក្រោម :

- នៅក្នុងក្រុមតូច ចូរគូរទីតាំងសំខាន់ៗ និងអាគារផ្សេងៗរបស់រដ្ឋាភិបាល ។
- ដាក់លើផែនទីនូវទីតាំងមុខរបរផ្សេងៗ ដោយផ្អែកលើចំណេះដឹងរបស់សមាជិកក្រុមរបស់អ្នក ។
- ក្រុមរបស់អ្នកចម្លងផែនទីនោះមួយច្បាប់សម្រាប់ឱ្យគ្រូ និងសមាជិកម្នាក់ៗត្រូវមាន ១ច្បាប់ដែរ ។

៣. គ្រូប្រមូលផែនទីចម្លងមុននឹងបំបែកក្រុមទៅផ្ទះ ។

| កិច្ចការផ្ទះ |
|---|

**កិច្ចការផ្ទះ ( សម្រាប់សិស្សម្នាក់ៗ)**

- ចូរកំណត់មុខរបរមួយទៀតដែលអាចបន្ថែមទៅលើផែនទីដែលក្រុមតូចបានធ្វើ ។
- ចូររកមុខរបរមួយដែលអ្នកមិនដែលដឹងពីមុនមក ។

## មេរៀនទី៤ ៖ ការចាប់អារម្មណ៍លើមុខរបរ និង ការស្រាវជ្រាវ

🕑 **រយៈពេលបង្រៀន** ២ ម៉ោង

☑ **ការរៀបចំរបស់គ្រូមុនពេលបង្រៀន**

- សំណួររំលឹកមេរៀន
- គ្រូពិនិត្យសៀវភៅសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរសម្រាប់សកម្មភាពដែលត្រូវបង្រៀនដែរឬទេ
- ក្រដាសផ្ទាំងធំសរសេរបញ្ជីសំណួរសម្រាប់សកម្មភាពទី៤

📖 **សម្ភារៈ**

- ឯកសារណែនាំសម្រាប់គ្រូ
- សៀវភៅសិស្ស
- សម្ភារៈបង្រៀនដែលមានរៀបចំខាងលើ
- ដីស និង ក្ដាខៀន
- កម្រងសំណួរ ខ្លឹមសារមេរៀន

☼ **លទ្ធផលសិក្សារំពឹងទុក**

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច ៖

- ប្រាប់ពីអារម្មណ៍ផ្ទាល់ខ្លួន លើជំនាញ និង មុខរបរ
- ធ្វើការស្រាវជ្រាវលំអិតលើជម្រើសមុខរបរ
- បង្កើតគំនិតពីប្រភេទផ្សេងៗនៃជម្រើសមុខរបរ
- កំណត់គុណសម្បត្តិ និង គុណវិបត្តិ នៃប្រភេទមុខរបរនីមួយៗ។

**លំនាំនៃការបង្រៀន**

| សកម្មភាពទី១ : រំលឹកកិច្ចការផ្ទះ ការគូរផែនទី | ⌚ ៣០ នាទី |
|---|---|

១. គ្រូឱ្យសិស្សក្រុមតូច កែសម្រួលផែនទីមុខរបរ ដោយដាក់បញ្ចូលមុខរបរថ្មីដែលសិស្សម្នាក់ៗបានរកឃើញ ។ (រយៈពេល ១០នាទី)

២. គ្រូឱ្យសិស្សដែលស្ម័គ្រចិត្តឡើងផ្តល់ចម្លើយ

- តើមុខរបរថ្មីអ្វីខ្លះដែលអ្នកបានរកឃើញ?
- តើអ្នករកឃើញមុខរបរនោះដោយរបៀបណា?
- តើអ្នកបានដឹងអ្វីខ្លះពីមុខរបរនោះ?

៣. គ្រូបង្ហាញពីប្រធានបទ និង វត្ថុបំណងសម្រាប់ថ្ងៃនេះ ។

ប្រសិនបើយើងចង់ពិចារណាអំពីជម្រើសមុខរបរដែលមានលក្ខណៈប្រាកដនិយម យើងចាំបាច់ត្រូវតែប្រមូលព័ត៌មាន និង ពិចារណាពីកត្តាផ្សេងៗដែលជះឥទ្ធិពលទៅលើដំណើរការដែលនាំយើងឆ្ពោះទៅដល់មុខរបរជាក់លាក់ណាមួយ ។ ថ្ងៃនេះយើងនឹងពិនិត្យមើលទៅលើកត្តាទាំងនោះ ថាតើវាមានទំនាក់ទំនងទៅនឹងគំនិតរបស់យើងអំពីមុខរបរនាពេលអនាគតដូចម្តេចខ្លះ ។

| សកម្មភាពទី ២ : ទេពកោសល្យ ជំនាញ បទពិសោធន៍ និង ចំណាប់អារម្មណ៍របស់ខ្ញុំ | ⌚ ២០ នាទី |
|---|---|

១. គ្រូទុកពេលឱ្យសិស្ស១០នាទី សម្រាប់កត់សំណួរចូលសៀវភៅរបស់ពួកគេ ។

- តើការងារអ្វីខ្លះដែលអ្នកចូលចិត្តធ្វើ?
- តើអ្នកគិតថា អ្នកមានទេពកោសល្យ និងជំនាញអ្វីខ្លះ?
- តើមុខវិជ្ជាអ្វីខ្លះដែលអ្នកចូលចិត្តសិក្សា?

២. គ្រូឱ្យសិស្សសរសេរឈ្មោះការងារទាំងនោះលើក្តារខៀន ។

➢ ចម្លើយរំពឹងទុក : (ចម្លើយត្រឹមត្រូវអាចមានច្រើនលើសពីមួយ) សិស្សអាចកំណត់ពីការងារដែលគេធ្វើដូចខាងក្រោម :

- អានសៀវភៅ គូររូប
- សាងសង់
- ហាត់ប្រាណ និង លេងកីឡា
- រៀនគណិតវិទ្យា រៀនលេខ
- និពន្ធ និង និទានរឿង
- ច្រៀង និង លេងភ្លេង
- ដាំដំណាំ និង ថែទាំដំណាំ
- ចិញ្ចឹមសត្វ ចិញ្ចឹមត្រី
- ជជែកជាមួយមិត្តភក្តិ
- ដេរប៉ាក់ ត្បាញ . . .

៣. គ្រូទុកឱកាសឱ្យសិស្ស ៥នាទី សម្រាប់កត់ត្រាចម្លើយចូលសៀវភៅ ។

- តើបទពិសោធន៍អ្វីខ្លះដែលអ្នកធ្លាប់មានហើយ?

៤. គ្រូសួរ : តើការងារអ្វីដែលអ្នកធ្លាប់បានធ្វើហើយ?

- ចម្លើយត្រឹមត្រូវរួមមាន
  - លក់ដូរក្នុងផ្សារ
  - ធ្វើការក្នុងកសិដ្ឋាន
  - ដាំស្ល
  - ដេរប៉ាក់
  - អ្នករត់សំបុត្រ ឬ ផ្តល់សេវាកម្ម
  - ជាងឈើ
  - ជាងម៉ាស៊ីន . . . ។

៥. គ្រូឱ្យសិស្សរៀបចំផែនទីមុខរបរ និង បញ្ជីដែលបានធ្វើនៅក្នុងល្បែងកំណត់ឈ្មោះ មុខរបរឱ្យបានត្រឹមត្រូវ ដើម្បីប្រើនៅក្នុងលំហាត់បន្ទាប់ ។

| សកម្មភាពទី៣ : មុខរបរសម្រាប់ខ្ញុំ | ២០ នាទី |
|---|---|

១. គ្រូណែនាំសិស្សធ្វើកិច្ចការដូចខាងក្រោម

- កំណត់មុខរបរមួយដែលអ្នកបានសរសេររៀបរាប់ពីអ្វីដែលអ្នកចង់ធ្វើ ឬ មានទេពកោសល្យ មានជំនាញ ឬ ធ្លាប់សិក្សា ។

- គ្រូឱ្យសិស្សរកឧទាហរណ៍

- ប្រសិនបើពុំសូវយល់ គ្រូអាចលើកជាឧទាហរណ៍ដូចខាងក្រោម :
  - ប្រសិនបើអ្នកចូលចិត្តគណិតវិទ្យា ដូចនេះអ្នកគួរតែយកជំនាញគណនេយ្យ ។

- ប្រសិនបើអ្នកចូលចិត្តសរសេរ ដូចនេះអ្នកគួរតែធ្វើជាអ្នកកាសែត ឬ អ្នកនិពន្ធ ។
- ប្រសិនបើអ្នកចូលចិត្តភាសាអង់គ្លេស អ្នកគួរតែធ្វើជាអ្នកកែសម្រួលអត្ថបទ ឬ ជាអ្នកបកប្រែ ឬ អ្នកនាំភ្ញៀវ ឬ អ្នកផ្សាយពាណិជ្ជកម្ម ។
- ប្រសិនបើអ្នកចូលចិត្តការនេសាទ និងកិច្ចការក្រៅផ្ទះដូចនេះ អ្នកគួរតែធ្វើជាអ្នកចិញ្ចឹមត្រី ឬកសិករ ឬ អ្នកថែសួនឧទ្យាន ។

២. គ្រូឱ្យសិស្សធ្វើការជាដៃគូររយៈពេល ១០នាទី ដើម្បី

- បង្កើតបញ្ជីមុខរបរដែលមានសក្តានុពលនឹងចំណាប់អារម្មណ៍ ឬទេពកោសល្យ និង ជំនាញរបស់គេ ។
- សរសេរបញ្ជីមុខរបរដែលមាននៅក្នុងល្បែងកំណត់ឈ្មោះមុខរបរ ឬ មុខរបរផ្សេងៗទៀតដែលអ្នកទើបនឹកឃើញ ។
- ដាក់រូបញញឹម ☺ នៅក្បែរឈ្មោះមុខរបរដែលអ្នកធ្លាប់មានបទពិសោធន៍ខ្លះៗ ។

៣. ឱ្យសិស្សចែករំលែកព័ត៌មានពីមុខរបររបស់ពួកគេ និង ពន្យល់ពីមូលហេតុដែលបណ្តាលឱ្យគេកំណត់យកមុខរបរនោះ ។

| សកម្មភាពទី ៤ : ការសិក្សាស្រាវជ្រាវពីជម្រើសមុខរបរ | ៣០ នាទី |
|---|---|

១.គ្រូពន្យល់សិស្ស

- យើងមានផែនការធ្វើសម្ភាសជាមួយបុគ្គលដែលអាចផ្តល់ឱ្យយើងនូវព័ត៌មានអំពីមុខរបរ ។
- ទុកពេល៥នាទីសម្រាប់កំណត់ពីមុខរបរដែលអ្នកអាចស្រាវជ្រាវ បន្ថែមទៀត តាមរយៈការធ្វើសម្ភាស (ជួបផ្ទាល់ ឬ តាមទូរសព្ទ) ជាមួយនឹងមនុស្សដែលធ្វើការងារនេះ នៅសប្តាហ៍បន្ទាប់ ។
- សិស្សត្រូវកំណត់មុខរបរមួយ ឬមុខរបរមួយជាក់លាក់ ដែលអ្នកបានជ្រើសរើសសម្រាប់សកម្មភាពនេះ ។

២.គ្រូបែកចែកសិស្សជាក្រុមតូច ដែលមានគ្នា៦ នាក់ហើយធ្វើការពន្យល់ដូចខាងក្រោម :

- ក្រុមរបស់អ្នកមានពេល ១៥ នាទី សម្រាប់ធ្វើសកម្មភាពនេះ ។
- ក្រុមនីមួយៗត្រូវដាក់ឈ្មោះមុខរបរដែលអ្នកចង់ធ្វើការសិក្សាបន្ថែមទៀតតាមរយៈការធ្វើសម្ភាស ។
- សមាជិកម្នាក់ៗនៅក្នុងក្រុមនីមួយៗត្រូវលើកជាគំនិត ឬ គិតពីមុខជំនួញដែលអ្នកត្រូវទៅសម្ភាស ។
- សមាជិកក្រុមម្នាក់ៗត្រូវមានផែនការច្បាស់លាស់ដែលអាចអនុវត្តបានសម្រាប់បញ្ចប់ការធ្វើសម្ភាសនេះ ។

# ឯកសារសម្រាប់គ្រូ

៣. គ្រូឱ្យសិស្សបង្ហាញពីមុខរបររបស់ពួកគេ និង បុគ្គលដែលគេត្រូវទៅសម្ភាសដល់សិស្សក្នុងថ្នាក់ ដើម្បីធ្វើឱ្យច្បាស់ថាក្រុមខ្លួនមានផែនការច្បាស់លាស់ ក្នុងការធ្វើសម្ភាស។

៤. គ្រូផ្ដល់ឱ្យសិស្សនូវបញ្ជីសំណួរសម្រាប់សួរនៅពេលធ្វើសម្ភាស

- ១. តើ បង/ពូ/មីង/អ៊ំ ធ្វើការជ្រើសរើសមុខរបរនេះយ៉ាងដូចម្ដេច?
- ២. សូម បង/ពូ/មីង/អ៊ំជួយពន្យល់ពីសកម្មភាពទូទៅ និងភារកិច្ចមួយចំនួនឱ្យខ្ញុំបានដឹងផង?
- ៣. តើបរិយាកាសជុំវិញម៉ោងធ្វើការ និង តម្រូវការខាងគំនិតប្រាជ្ញា និង កាយសម្បទា មានលក្ខណៈយ៉ាងណាខ្លះសម្រាប់ការងារនេះ?
- ៤. តើខ្ញុំត្រូវមានការអប់រំ និងបទពិសោធន៍អ្វីខ្លះដើម្បីធ្វើមុខរបរនេះ?
- ៥. តើអ្វីដែលបង/ពូ/មីង/អ៊ំ ចូលចិត្តបំផុតសម្រាប់ការងារនេះ?
- ៦. តើអ្វីដែលបង/ពូ/មីង/អ៊ំមិនសូវចូលចិត្ត សម្រាប់ការងារនេះ?
- ៧.តើបង/ពូ/មីង/អ៊ំគិតថាការងារប្រភេទនេះជាតម្រូវការសម្រាប់អនាគតរបស់ខ្ញុំដែរឬទេ?
- ៨.តើបង/ពូ/មីង/អ៊ំអាចប្រាប់ខ្ញុំបានទេពីប្រាក់ខែចាប់ផ្ដើមដំបូងសម្រាប់ការងារនេះ?
- ៩. តើបង/ពូ/មីង/អ៊ំមានការណែនាំអ្វីខ្លះសម្រាប់យុវជនជំនាន់ក្រោយដូចជាយើងខ្ញុំ ប្រសិនបើយើងខ្ញុំចង់រៀបចំការងារមួយស្រដៀងគ្នាបែបនេះ?
- ១០. (អ្នកអាចបន្ថែមសំណួរផ្ទាល់ខ្លួន ប្រសិនបើអ្នកចង់សួរ)

៥. សិស្សធ្វើការកត់ត្រាសំណួរទាំងនេះចូលក្នុងសៀវភៅ សិស្សអាចមើលខ្លឹមសារទាំងនេះនៅក្នុងសៀវភៅសិស្ស។

៦. គ្រូណែនាំពីរបៀបប្រកាន់ឥរិយាបថសម្រាប់ការធ្វើសម្ភាស

- ត្រូវចេះគួរសម និង សុភាពរាបសា
- ធ្វើការណែនាំខ្លួន
- ប្រាប់ពីគោលបំណងនៃការធ្វើសម្ភាស
- សុំពេលវេលាសម្រាប់ធ្វើសម្ភាស
- ថ្លែងអំណរគុណពេលចប់សម្ភាស។

៧. គ្រូសួរសិស្ស តើគេមានអ្វីត្រូវបន្ថែមទៀតដែរឬទេ?

# ឯកសារសម្រាប់គ្រូ

**កិច្ចការផ្ទះ**

- សិស្សធ្វើសម្ភាស ។
- សិស្សសរសេររបាយការណ៍ ។
- សិស្សរៀបចំធ្វើបទបង្ហាញអំពីអ្វីដែលដែលគេរកឃើញលើសំណួរទាំងអស់ ។

  (កំណត់សម្គាល់ ៖ អ្នកមានពេល៥ នាទីសម្រាប់ធ្វើបទបង្ហាញសង្ខេប ។ គ្រូអាចបង្កើនពេលបន្ថែម ប្រសិនបើមានសិស្សតិចជាង ១២ នាក់នៅក្នុងក្រុម) ។
- ធ្វើការអនុវត្តសាកល្បងជាមុន ហើយរក្សាទុកតែចំណុចសង្ខេបដែលសំខាន់ និង គួរចាប់អារម្មណ៍ ។

## មេរៀនទី៥ : ការធ្វើសម្ភាសពីមុខរបរ

**រយៈពេលបង្រៀន** ២ ម៉ោង

**ការរៀបចំរបស់គ្រូមុនពេលបង្រៀន**

- គ្រូរំលឹកមេរៀន
- គ្រូពិនិត្យមើលសៀវភៅសិស្ស ដើម្បីចង់ដឹងពីព័ត៌មាន និង សំណួរសម្រាប់សកម្មភាពដែលត្រូវបង្រៀន
- រៀបចំសម្ភារៈសម្រាប់បង្រៀន ។

**សម្ភារៈ**

- ឯកសារណែនាំសម្រាប់គ្រូ
- សៀវភៅសិស្ស
- សម្ភារៈបង្រៀនដូចដែលមានរៀបចំខាងលើ
- ក្រដាសផ្ទាំងធំសរសេរបញ្ជីសំណួរសម្ភាសដែលបានសរសេរទុកជាមុន
- ដីស និង ក្ដារខៀន
- ក្រដាសផ្ទាំងធំ ហ្វឺត និង បញ្ជីឈ្មោះសិស្ស
- កម្រងសំណួរ ខ្លឹមសារមេរៀន ។

**លទ្ធផលសិក្សារំពឹងទុក**

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច :

- ប្រាប់ពីអារម្មណ៍ផ្ទាល់ខ្លួន លើជំនាញ និង មុខរបរ
- ធ្វើការស្រាវជ្រាវលំអិតលើជម្រើសមុខរបរ
- បង្កើតគំនិតអំពីប្រភេទផ្សេងៗនៃជម្រើសមុខរបរ ។

**លំនាំនៃការបង្រៀន**

| សកម្មភាពទី១ : ការបង្ហាញពីការធ្វើសម្ភាសមុខរបរ | ៧០ នាទី |
|---|---|

១, គ្រូចែកសិស្សជាក្រុមតូចចំនួន ២-៣ ក្រុម ( ក្រុមនីមួយៗមានគ្នាមិនលើសពី ១៥នាក់) ។

២, ក្រុមនីមួយៗទៅកន្លែងផ្សេងគ្នាដើម្បីធ្វើបទបង្ហាញពីការសម្ភាស

- សិស្សម្នាក់ៗមានពេល៥នាទី ( គ្រូអាចបង្កើនពេលបន្ថែមប្រសិនបើមានសិស្សតិចជាង១២ ក្នុងមួយក្រុម )
- ក្រុមនីមួយៗ ត្រូវចាត់សមាជិកម្នាក់សម្រាប់កំណត់ពេល ( អ្នកមើលម៉ោង) ។

| សកម្មភាពទី២ : ការពិភាក្សាសង្ខេបលើលទ្ធផលនៃការធ្វើសម្ភាសមុខរបរ | ៣០ នាទី |
|---|---|

**គ្រូសួរ**

- តើអ្នកមានការភ្ញាក់ផ្អើលពីលទ្ធផលនៃមុខរបរអ្វី?
- តើអ្នកចាប់អារម្មណ៍លើមុខរបរអ្វីជាងគេ? ហេតុអ្វី?
- ចូរប្រៀបធៀបពីមុខរបរដែលអ្នកបានដឹងពីមុនៗ តើមុខរបរណាល្អជាងគេ សូមធ្វើការពន្យល់?
- តើការណែនាំអ្វីខ្លះដែលអ្នកគិតថាមានប្រយោជន៍ក្នុងការធ្វើផែនការមុខរបរសម្រាប់អនាគត?
- តើមុខរបរអ្វីខ្លះដែលអ្នកចង់សិក្សាបន្ថែម ប៉ុន្តែមិនអាចរកអ្នកសម្ភាសបាន?

| កិច្ចការផ្ទះ |
|---|

- ផ្អែកលើសំណួរដែលបានពិភាក្សាទាំង ៥ ខាងលើ ចូរសរសេរនៅក្នុងសៀវភៅកត់ត្រាពីការយល់ឃើញផ្ទាល់ខ្លួនរបស់អ្នក ។

## មេរៀនទី៦ : ការធ្វើផែនការសម្រាប់អនាគតអ្នក

**រយៈពេលបង្រៀន** ២ ម៉ោង (១០០នាទី)

**ការរៀបចំរបស់គ្រូមុនពេលបង្រៀន**

- គ្រូរំលឹកមេរៀន
- ពិនិត្យសៀវភៅសិស្ស
- គ្រូសរសេរសំណួរពិភាក្សាក្រុមសម្រាប់សកម្មភាពទី ៣, ៤, ៥ នៅលើក្ដារខៀន ឬ នៅលើក្រដាសផ្ទាំធំ ។

**សម្ភារៈ**

- ឯកសារណែនាំសម្រាប់គ្រូ
- សៀវភៅសិស្ស
- សម្ភារៈបង្រៀនដូចដែលបានរៀបចំខាងលើ
- ក្រដាសផ្ទាំងធំសរសេរពីវិធីសាស្ត្រធ្វើផែនការដើម្បីសមរេចគោលដៅ
- ដីស និង ក្ដារខៀន
- ក្រដាសផ្ទាំងធំ ហ្វឺត និង បញ្ជីឈ្មោះសិស្ស ។

**លទ្ធផលសិក្សារំពឹងទុក**

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច :

- ប្រើប្រាស់វិធីសាស្ត្រធ្វើផែនការគោលដៅ ៤ +២ ដើម្បីធ្វើការជ្រើសរើសមុខរបរមួយ
- កំណត់ផែនការជាក់លាក់សម្រាប់ធ្វើមុខរបរនោះ ។

## លំនាំនៃការបង្រៀន

| សកម្មភាពទី១ : ពិនិត្យឡើងវិញពី វិធីសាស្ត្រធ្វើផែនការដើម្បីសំរេចគោលដៅ | ១០ នាទី |
|---|---|

១. គ្រូណែនាំសិស្សឱ្យជ្រើសរើសមុខរបរដែលមានចំណាប់អារម្មណ៍ពិតប្រាកដ សម្រាប់យកមកសិក្សា។

២. គ្រូរំលឹកពីដំណើរការធ្វើផែនការដើម្បីសំរេចគោលដៅ

- គ្រូរំលឹកពី ធាតុទាំង៤ក្នុងការសរសេរគោលដៅ
    - **អ្នកណា?** គោលដៅគឺសម្រាប់ខ្លួនអ្នក
    - **អ្វី?** គឺអ្វី ដែលអ្នកចង់សម្រេចបាន?
    - **នៅទីណា?** តើទីណាដែលអ្នកចង់ទៅដល់ដើម្បីសម្រេចគោលដៅនោះ?
    - **ពេលណា?** នៅពេលណាដែលអ្នកសង្ឃឹមថាអ្នកអាចសម្រេចគោលដៅនោះបាន?
- គ្រូនឹងរំលឹកពីធាតុទាំង ២ ក្នុងការធ្វើផែនការដើម្បីសំរេចគោលដៅ
    - ៤+១ "**ធ្វើដូចម្តេច?**" តើអ្នកអាចសម្រេចវាបានយ៉ាងដូចម្តេច?
        - **សកម្មភាព :** តើមានសកម្មភាពអ្វីខ្លះដែលត្រូវការចាំបាច់ដើម្បីឈានទៅដល់គោលដៅរបស់អ្នក?
        - **សេចក្តីត្រូវការ :** ដើម្បីសម្រេចគោលដៅនេះ តើអ្នកត្រូវការអ្វី(ការអប់រំ បទពិសោធន៍ ធនធាន បណ្តាញគាំទ្រ)?
    - ៤+២ "**ភាពអាចធ្វើបាន**" តើគោលដៅនេះមានភាពប្រាកដនិយមនិងអាចសម្រេចបានដែរឬទេ?

៣. គ្រូសួរតើមានសំណួរ ឬ អនុសាសន៍អំពីវិធីសាស្ត្រធ្វើផែនការដើម្បីសំរេចគោលដៅដែរឬទេ?

៤. គ្រូពន្យល់

យើងប្រើវិធីសាស្ត្រធ្វើផែនការដើម្បីសំរេចគោលដៅ ៤+២ ដើម្បីធ្វើផែនការឱ្យសម្រេចគោលដៅមុខរបររបស់យើង។ យើងធ្វើការពិចារណាពីអ្វីដែលយើងបានគិត និង រៀនរយៈពេល២-៣ សប្តាហ៍កន្លងមក និង ព្យាយាមកំណត់មុខរបរខ្លះ ដែលអាចសម្រេចបានដោយស្របនឹងចំណាប់អារម្មណ៍ និងទេពកោសល្យរបស់យើង។

៥. គ្រូធ្វើការរំលឹកពីគោលបំណងមេរៀន។

| សកម្មភាពទី ២ : ការសម្រេចចិត្តលើការជ្រើសរើសមុខរបរ | ១៥ នាទី |
|---|---|

១. គ្រូពន្យល់ យើងត្រូវប្រើវិធីសាស្ត្រធ្វើផែនការដើម្បីសំរេចគោលដៅ ដើម្បីកំណត់ចេញនូវវិធីឆ្ពោះទៅរកជម្រើសមុខរបររបស់យើង សម្រាប់ធ្វើលំហាត់នេះ ។

២. គ្រូឱ្យសិស្សធ្វើកិច្ចការដូចខាងក្រោម

- រើសយកគំនិតមួយសម្រាប់ជម្រើសមុខរបរដែលមានសក្តានុពលដោយផ្អែកលើៈ
  - ការពិនិត្យឡើងវិញលើកដំបូងរបស់អ្នកពីចំណាប់អារម្មណ៍ ទេពកោសល្យ និង ជំនាញ
  - បទពិសោធន៍ធ្វើសម្ភាសរបស់អ្នក
  - ចំណាប់អារម្មណ៍លើមុខរបរថ្មីដែលអ្នកបានរៀន ឬ បានគិតកាលពីពេល២-៣សប្តាហ៍កន្លងមក ។
- សរសេរពីជម្រើសមុខរបរដែលជាគោលដៅដែលអ្នកចង់ឱ្យសម្រេច ដោយរួមបញ្ចូលធាតុទាំង ៤ ។

៣. គ្រូឱ្យសិស្សពិនិត្យគោលដៅរបស់ខ្លួនជាមួយនឹងសិស្សដែលនៅអង្គុយជិតគ្នា ហើយធ្វើការកែលំអ ឬផ្លាស់ប្តូរគោលដៅរបស់ខ្លួន ។

| សកម្មភាពទី ៣ :ការធ្វើផែនការដើម្បីសំរេចគោលដៅមុខរបរ ដោយប្រើ វិធីសាស្ត្រ ៤ +២ | ២០ នាទី |
|---|---|

១. គ្រូឱ្យសិស្ស

- ប្រើប្រាស់គោលដៅមុខរបរដែលអ្នកទើបនឹងសរសេរ រួចសរសេរតាមវិធីសាស្ត្រ ៤ +១ "**ធ្វើដូចម្តេច**" ដោយចាប់ផ្តើមពីសកម្មភាព និងសេចក្តីត្រូវការដើម្បីឈានទៅសម្រេចគោលដៅនោះ ។
- ក្រោយពីបញ្ចប់កិច្ចការនេះ អ្នកត្រូវសួរខ្លួនឯងថា "តើគោលដៅនេះអ្នកអាចធ្វើបាន ឬ អាចសម្រេចបាន និង មានលក្ខណៈប្រាកដជាក់លាក់ដែរឬទេ?"
- ប្រសិនបើចម្លើយ **ទេ** សូមពិនិត្យមើលគោលដៅ និង ចម្លើយចំពោះសំណួរ "**ធ្វើដូចម្តេច?**" ធ្វើដូចនេះ ចម្លើយរបស់អ្នកសម្រាប់៤+២ គឺ **ចាស/បាទ** ។
- អ្នកអាចចាប់ផ្តើមដាក់ឈ្មោះសកម្មភាពដើម្បីឈានទៅសម្រេចគោលដៅទាំងនោះ ។
- ធ្វើឱ្យរួចក្នុងរយៈពេល៥នាទីហើយធ្វើការបង្ហាញផែនការរបស់អ្នកដោយសង្ខេប ។

| សកម្មភាពទី៤ : ការចែករំលែកផែនការដើម្បីសំរេចគោលដៅមុខរបររបស់អ្នក | ៤០ នាទី |
|---|---|

១. គ្រូចែកសិស្សជាក្រុមតូច ដែលមានគ្នា ៦ នាក់ ។

២. ទុកពេល៥នាទីឱ្យសិស្សធ្វើការបង្ហាញគោលដៅរបស់ពួកគេក្នុងក្រុមតូច ។

៣. ក្រោយពីធ្វើការបង្ហាញសមាជិកក្រុមមានឱកាសផ្ដល់ព័ត៌មានត្រឡប់ដូចខាងក្រោម :

- តើមានធាតុទាំង៤នៅក្នុងគោលដៅនោះឬទេ?
- តើពាក្យ "**ធ្វើដូចម្ដេច** " បានបញ្ជាក់ច្បាស់លាស់ពីសកម្មភាព និងសេចក្ដីត្រូវការដែរឬទេ?
- តើពួកគេគិតថាគោលដៅនោះអាចសម្រេចបានដែរឬទេ ? បាន ឬ មិនបាន មូលហេតុអ្វី?
- សិស្សដែលឡើងបង្ហាញត្រូវធ្វើការកត់ត្រាព័ត៌មានត្រឡប់ នឹងធ្វើការកែលំអ គោលដៅមុខរបរជាចុងក្រោយមុនពេលប្រគល់កិច្ចការជូនគ្រូ ។

| សកម្មភាពទី ៥: ពិភាក្សាពីការប្រឈមចំពោះគោលដៅ និង ការធ្វើផែនការ | ១៥ នាទី |
|---|---|

គ្រូសួរ

- តើបញ្ហាប្រឈមអ្វីខ្លះដែលអ្នកបានជួបប្រទះក្នុងការធ្វើផែនការគោលដៅមុខរបរដែលប្រើវិធីសាស្ត្រ ៤ +២?
- ដើម្បីគិតពីគោលដៅមុខរបររបស់អ្នក ចូរអ្នកកំណត់បញ្ហាប្រឈមដែលអ្នកអាចជួបប្រទះក្នុងដំណើរការឆ្ពោះទៅរកគោលដៅនេះ?
- តើមានសកម្មភាពបន្ទាន់ណាមួយដែលអ្នកបានពិភាក្សាគ្នានៅក្នុងក្រុមរបស់អ្នកហើយដែលអាចនាំអ្នកទៅដល់ការសម្រេចគោលដៅមុខរបរខ្លះដែរឬទេ?

| កិច្ចការផ្ទះ |
|---|

- ចូរធ្វើការកែលំអគោលដៅមុខរបរតាមវិធីសាស្ត្រ ៤ +២ មុនពេលប្រគល់កិច្ចការជូនគ្រូ ។
- ចូរអានករណីសិក្សារបស់ថានីមុនពេលចាប់ផ្ដើមរៀនមេរៀនបន្ទាប់ទៀត ។
- ចូរអានពីដំណោះស្រាយសម្រាប់ករណីសិក្សារបស់ថានីផងដែរ ។

## មេរៀនទី៧ : ការធ្វើសេចក្ដីសម្រេចចិត្ត

**រយៈពេលបង្រៀន** ២ ម៉ោង

### ☑ ការរៀបចំរបស់គ្រូមុនបង្រៀន

- គ្រូរំលឹកមេរៀន
- គ្រូពិនិត្យមើលសៀវភៅសិស្ស ដើម្បីចង់ដឹងពីព័ត៌មាន និង សំណួរ ។
- សរសេរលំនាំនៃការធ្វើសេចក្ដីសម្រេចចិត្តនៅលើក្រដាសផ្ទាំងធំ ។ ប្រសិនបើសិស្សមានសៀវភៅគេអាចមើលខ្លឹមសារទាំងនេះនៅក្នុងសៀវភៅរបស់គេ ។
- សរសេរពីយុទ្ធវិធីនៃការធ្វើសេចក្ដីសម្រេចចិត្ត ឬ លក្ខណៈនៃការធ្វើសេចក្ដីសំរេចចិត្តនៅលើក្រដាសតូចសម្រាប់ចែកឱ្យសិស្ស ។ ប្រសិនបើសិស្សមានសៀវភៅគេអាចមើលខ្លឹមសារទាំងនេះនៅក្នុងសៀវភៅរបស់គេ ។
- រៀបចំកម្រងសំណួរ និងខ្លឹមសារមេរៀន

### សម្ភារៈ

- ឯកសារណែនាំសម្រាប់គ្រូ
- សៀវភៅសិស្ស
- សម្ភារៈបង្រៀនដែលបានរៀបចំខាងលើ
- ប្រអប់ ម្មូក សម្រាប់ឱ្យសិស្សចាប់យកក្រដាសចេញ
- ដីស និង ក្ដារខៀន
- ក្រដាស់ផ្ទាំងធំ ហ្វឺត និង បញ្ជីឈ្មោះសិស្ស ។

### ☼ លទ្ធផលសិក្សារំពឹងទុក

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច :

- កំណត់ដំណាក់កាលនៃដំណើរការធ្វើការសម្រេចចិត្ត
- កំណត់កត្តាដែលជះឥទ្ធិពលលើដំណើរការសម្រេចចិត្ត និងផលវិបាកក្នុងការធ្វើការសម្រេចចិត្ត
- កំណត់វិធីឈានទៅរកមុខរបរ និងធ្វើផែនទីបង្ហាញផ្លូវតាមផែនការឆ្ពោះទៅរកមុខរបរនោះ ។

**លំនាំនៃការបង្រៀន**

| សកម្មភាពទី ១ : ការណែនាំពីការធ្វើសេចក្តីសម្រេចចិត្ត | ១០ នាទី |
|---|---|

១. គ្រូពន្យល់

ដំណើរផ្លូវឆ្ពោះទៅរកការសម្រេចគោលដៅតែងមានឧបសគ្គ និង បញ្ហាប្រឈមជាច្រើនកើតឡើង ។ វាជាការសំខាន់សម្រាប់សិស្សធ្វើការពង្រឹងជំនាញក្នុងការធ្វើសេចក្តីសម្រេចចិត្ត ប្រកបដោយភាពវៃឆ្លាត និង ឆ្ពោះទៅរកគោលដៅ ។

- ការសម្រេចចិត្តមួយចំនួនមានភាពងាយស្រួល ។ ឧទាហរណ៍ តើយើងត្រូវជ្រើសរើសយកមុខម្ហូបមួយណាសម្រាប់អាហារពេលព្រឹក?
- ការសម្រេចចិត្តខ្លះមិនមានភាពងាយស្រួលនោះទេ ។ ឧទាហរណ៍ តើយើងត្រូវនៅផ្ទះដើម្បីមើលសាច់ញាតិដែលមានជំងឺ ឬយើងត្រូវទៅសាលារៀន?

២. គ្រូសួរ

- ចូរផ្តល់ឧទាហរណ៍ផ្សេងទៀតស្តីពីការសម្រេចចិត្តដែលមានភាពងាយស្រួល ។
- ចូរផ្តល់ឧទាហរណ៍ផ្សេងទៀតស្តីពីការសម្រេចចិត្តដែលមិនមានភាពងាយស្រួល ។

៣. គ្រូប្រាប់ពីគោលបំណងនៃមេរៀននេះ

៤. មានជំហានជាច្រើនសម្រាប់ធ្វើការសម្រេចចិត្តប្រកបដោយការគិតគូរដ៏ត្រឹមត្រូវក្នុងការការសម្រេចចិត្ត ដែលមានការលំបាកដែលអ្នកជួបប្រទះ ។ គោលគំនិតនៃការធ្វើការសម្រេចចិត្ត ដែលយើងត្រូវអនុវត្តរួមមាន:

- ការកំណត់បញ្ហា
- ការប្រមូលព័ត៌មាន ពិចារណាលើដំណោះស្រាយ
- បញ្ជីស្តីពីការសម្រេចចិត្តផ្សេងៗ
- ការពិចារណាលើផលវិបាកក្នុងការសម្រេចចិត្តផ្សេងៗ
- ការជ្រើសរើសវិធីក្នុងការធ្វើការសម្រេចចិត្តល្អបំផុត

| សកម្មភាពទី ២ : យុទ្ធវិធីធ្វើការសម្រេចចិត្ត ឬ លក្ខណៈសម្គាល់ | ២០ នាទី |
|---|---|

១. គ្រូឱ្យសិស្សកំណត់កត្តាដែលមានឥទ្ធិពលទៅលើការសម្រេចចិត្ត។ ឧទាហរណ៍: តើយើងត្រូវនៅផ្ទះដើម្បីមើលសាច់ញាតិដែលមានជំងឺ ឬយើងត្រូវសម្រេចចិត្តទៅសាលារៀន ទាំងដឹងថានៅផ្ទះមានការលំបាកក៏ដោយ។

- តើអ្នកគិតអំពីអ្វី នៅពេលដែលអ្នកត្រូវសម្រេចចិត្តលើរឿងនេះ?
  - ចម្លើយរំពឹងទុករួមមាន
    - តើខ្ញុំត្រូវរកអ្នកណាមកជួយកិច្ចការផ្ទះនេះ ឬយ៉ាងណា?
    - តើខ្ញុំនឹងទទួលបានចំណាត់ថ្នាក់ក្រោយគេ ហើយមិនអាចប្រឡងជាប់ដែរឬទេ?
    - តើមិត្តរបស់ខ្ញុំនឹងបន្តធ្វើកិច្ចការនេះដោយគ្មានរូបខ្ញុំបានដែរឬទេ?
    - តើខ្ញុំអាចមិនធ្វើការផ្ទះបានដែរឬទេ?
    - តើគ្រួសាររបស់ខ្ញុំគិតយ៉ាងណាចំពោះខ្ញុំ ប្រសិនបើខ្ញុំមិនជ្រើសយកការងារនៅផ្ទះនិងជួយពួកគេ?
    - ប្រសិនបើខ្ញុំបោះបង់ការសិក្សា នោះខ្ញុំមិនអាចវិលត្រឡប់ទៅសាលារៀនវិញបានទេ។

២.ពន្យល់

យើងបានដឹងតាមរយៈចម្លើយខាងលើ ប្រសិនបើយើងឈប់គិតពីការសម្រេចចិត្តដែលយើង បានធ្វើពីមុន នោះយើងពិតជាមានគំនិតច្រើន។ នៅពេលដែលយើងធ្វើការសម្រេចចិត្ត តម្លៃរបស់យើង ដៃគូ ទម្លាប់ អារម្មណ៍ គ្រួសារ ការប្រថុយ និង ផលវិបាក អាយុ និង រឿងរ៉ាវជាច្រើនទៀតអាចមានឥទ្ធិពលលើការសម្រេចចិត្តដែលយើងត្រូវធ្វើ។

៣, គ្រូកំណត់យុទ្ធវិធីឬ លក្ខណៈសម្គាល់នៃការធ្វើការសម្រេចចិត្តមួយចំនួនដូចខាងក្រោម :

១, ការធ្វើឡើងដោយឯងៗ (ការជ្រើសរើសដោយមិនបានគិត កើតឡើងភ្លាមៗដោយមិនមានជម្រើសពិចារណាផ្សេងៗ)

២, ភាពស្របគ្នា (ផ្តល់តាមការសង្ឃឹមទុក ឬមានសម្ពាធពីអ្នកដទៃ)

៣, ការពន្យារពេល (ពន្យារពេលពីមួយថ្ងៃទៅមួយថ្ងៃរហូតដល់ការជ្រើសរើសកាន់តែមានកម្រិតតិច)

៤, ចេតនាចង់បាន (មានចំណង់ខ្លាំង ដោយមិនបានគិតពីផលវិបាក ឬ តម្លៃ)

៥, ការគេចវេះ (ការជៀសពីការលំបាក ការមិនចូលចិត្ត ឬ ភាពមិនសមគួរ)

៦, សន្តិសុខ (ការសម្រេចចិត្តដែលមានសុវត្ថិភាព មានការប្រថុយតិច ឬ ផលវិបាកតិច )

៧, បំណងប្រាថ្នា (ស្របជាមួយ គោលបំណង និង គោលដៅ)

៨. ភាពសមហេតុផល (ដោយធ្វើការថ្លឹងថ្លែងពីការគាំទ្រ និង ប្រឆាំង)

៩. ភាពងាយស្រួល (ជម្រើសដែលមើលទៅហាក់ដូចជាងាយស្រួលបំផុត)

៤. គ្រូលើកឧទាហរណ៍ពីស្ថានភាពដែលមនុស្សម្នាក់ធ្វើការសម្រេចចិត្ត ដោយប្រើយុទ្ធវិធី ឬ លក្ខណៈសម្គាល់ផ្សេងៗនៃការធ្វើសេចក្តីសម្រេចចិត្ត។

**ឧទាហរណ៍ :** ឈ្មោះយុទ្ធវិធី ការធ្វើឡើងដោយឯងៗ។ ខ្ញុំហួសម៉ោងទៅសាលា ដូចនេះខ្ញុំរត់ទៅសាលានៅពេលខ្ញុំចប់ការងារជួយលក់ដូរម្តាយរបស់ខ្ញុំ។ ដោយប្រញាប់ពេកខ្ញុំបានសម្រេចទិញទំនិញពីអ្នកលក់នៅក្បែរនោះដើម្បីសន្សំពេលវេលាជាជាងដើរទៅទិញនៅកន្លែងដែលខ្ញុំធ្លាប់ទៅ។

៥. ក្រោយពីឱ្យឧទាហរណ៍ពីយុទ្ធវិធីសម្រាប់ធ្វើសេចក្តីសម្រេចចិត្តរួចមក គ្រូសួរទៅសិស្សថា :

- តើយុទ្ធវិធីទាំងអស់អាចប្រើប្រាស់បានឬទេ? ហេតុអ្វី? (នេះជាការយល់ឃើញមួយ។ វាអាចមានចម្លើយត្រឹមត្រូវច្រើន។ យុទ្ធវិធីមួយចំនួនក៏មិនល្អដែរ ។ ឧទាហរណ៍ : ការពន្យារពេល ឬ ការគេចវេះ)
- តើយុទ្ធវិធីណាមួយល្អប្រសើរបំផុតដើម្បីប្រើក្នុងការសម្រេចចិត្តរយៈពេលយូរ? (ចម្លើយ : ចេតនា និង ភាពសមហេតុផល)

៦. គ្រូឱ្យសិស្សប្រាប់ពីកត្តាសេដ្ឋកិច្ចដែលអាចមានឥទ្ធិពលលើការសម្រេចចិត្ត?
(ប្រាក់ដែលមាននៅពេលបច្ចុប្បន្ន ឬ មាននៅពេលអនាគត ទ្រព្យសម្បត្តិ ឬ វត្ថុជាកម្មសិទ្ធិផ្សេងៗ ។ល។)

| សកម្មភាពទី ៣ : ករណីសិក្សាស្តីពីការសម្រេចចិត្ត | ៣០ នាទី |
|---|---|

១. គ្រូផ្តល់ករណីសិក្សាខាងក្រោម :

ថានីបានរៀនចប់ថ្នាក់ទី៨។ គេជាសិស្សល្អម្នាក់ដែលមានការសប្បាយនឹងការសិក្សាពីអ្វីថ្មីៗ និងជួយមិត្ត។ គ្រួសារថានីមានការលំបាកព្រោះគ្រួសារគេមានភាពក្រីក្រ។ ពួកគេមិនមានប្រាក់ច្រើនសម្រាប់ផ្តល់ឱ្យបងប្រុសរបស់គេរៀបការទេ។ ថានី មានជំនាញដូចជា ធ្វើគ្រឿងអលង្ការ និងជួសជុលម៉ូតូ។ គ្រួសារថានីគិតថា គេគួរតែឈប់រៀនដើម្បីធ្វើការពេញម៉ោងសម្រាប់រកប្រាក់មកឱ្យគ្រួសារ។

ជីវិតរបស់គេកាន់តែមានការលំបាកទៅៗ និងកាន់តែលែងមានភាពសប្បាយរីករាយ ដោយសារតែមានការខ្វះខាត ដូចនេះគេត្រូវតែធ្វើការសម្រេចចិត្តធ្វើអ្វីមួយ។

២. គ្រូដឹកនាំ

- កំណត់បញ្ហា

- ប្រមូលព័ត៌មាន ពិចារណាលើដំណោះស្រាយ និង ធ្វើបញ្ជីការសម្រេចចិត្តផ្សេងៗ
- ពិចារណាលើផលវិបាកនៃការសម្រេចចិត្តផ្សេងៗ
- ជ្រើសរើសសកម្មភាពដែលល្អបំផុត

៣. ក្រោយពីពិភាក្សាគ្នា គ្រូអាចបន្ថែមចំណុចដែលគាត់គិតថាមានសារៈសំខាន់។ (ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលខ្លឹមសារទាំងនេះនៅក្នុងសៀវភៅរបស់គេ)។

➢ **ការកំណត់បញ្ហា :** ថានីចង់នៅរៀនបន្ត ប៉ុន្តែគ្រួសារគាត់ឱ្យគាត់បោះបង់សាលា។

➢ **ការស្វែងរកព័ត៌មាន :**

- ថានី ទៅកន្លែងធ្វើគ្រឿងអលង្ការក្នុងមូលដ្ឋាន និង កន្លែងជួសជុលម៉ូតូដើម្បីស្វែងរកការងារធ្វើពាក់កណ្តាលម៉ោង ឬ ពេញម៉ោង ដើម្បីបានប្រាក់កម្រៃតាមម៉ោង ឬ តាមសប្តាហ៍ ឬ ការបត់បែននៃពេលវេលាតាមកាលវិភាគរបស់គាត់ ដើម្បីដោះស្រាយតម្រូវការម៉ោងសិក្សាសាលា។
- ថានីត្រូវធ្វើការស្វែងយល់ពីជម្រើសផ្សេងទៀតដែលសមាជិកគ្រួសារអាចរកប្រាក់ចំណូល។

➢ **ការធ្វើការពិចារណាទៅលើផលវិបាកនៃដំណោះស្រាយនីមួយៗ**

| **ដំណោះស្រាយ** | **ផលវិបាក** | |
|---|---|---|
| | **វិជ្ជមាន** | **អវិជ្ជមាន** |
| ថានីគួរឈប់រៀន ដូចដែលគ្រួសារចង់បាន ហើយទៅធ្វើគ្រឿងអលង្ការ និងជួសជុលម៉ូតូ។ | ○ ជម្រើសអនាគតរបស់គាត់កាន់តែមានកម្រិតប៉ុន្តែគាត់អាចទទួលបានការហ្វឹកហ្វឺន និងបទពិសោធន៍ក្នុងការធ្វើគ្រឿងអលង្ការនិង ជួសជុលម៉ូតូ។<br>○ គេមានមធ្យោបាយរកប្រាក់ចំណូល ប៉ុន្តែវាមិនអស្ចារ្យទេ។<br>○ គ្រួសាររបស់គាត់នឹងសប្បាយរីករាយ។ | ○ បោះបង់ការសិក្សានៅត្រឹមថ្នាក់ទី ៨គឺ វាជាការលំបាក ឬ មិនអាចមានលទ្ធភាពក្នុងការចូលរៀនវិញ។<br>○ គេអាចបោះបង់ឱកាសមុខរបរ វិជ្ជាជីវៈនាពេលអនាគតដែលធ្វើឱ្យគេទទួលបានប្រាក់ច្រើន។<br>○ គេនឹងមិនសប្បាយចិត្ត។<br>○ គេនឹងនឹកមិត្តរួមថ្នាក់របស់គេ ព្រមទាំងលែងបានជួបពួកគេជារៀងរហូត។ |
| ថានីនៅតែទៅសាលារៀន និងធ្វើការពាក់កណ្តាលម៉ោង។ | ○ គេមានឱកាសអាចទៅរៀនបន្តនៅវិទ្យាល័យនិងត្រៀមប្រឡងបញ្ចប់វិទ្យាល័យដែលជាសញ្ញាប័ត្រដ៏មានសារប្រយោជន៍។<br>○ គេមានការសប្បាយក្នុងការបន្តការសិក្សា។ | ○ គេនឹងមិនអាចទទួលប្រាក់ច្រើនសម្រាប់គ្រួសារ ដូចការធ្វើការងារពេញម៉ោងនោះទេ។<br>○ គេនឹងមានការហត់នឿយពីការធ្វើការផងរៀនផង។<br>○ គ្រួសារគាត់មិនមានការពេញចិត្តទាំងស្រុងទេ។<br>○ បងប្រុសរបស់គេគ្មានប្រាក់រៀបការ។<br>○ គេនឹងមានពេលតិចតួចសម្រាប់ការកំសាន្ត និង |

| ដំណោះស្រាយ | ផលវិបាក | |
| --- | --- | --- |
| | វិជ្ជមាន | អវិជ្ជមាន |
| | ○ គេនឹងទទួលបានប្រាក់ចំណូលខ្លះៗ សម្រាប់គ្រួសារ ។<br>○ គ្រួសាររបស់គេ មិនសប្បាយចិត្ត ។ | ការនៅជាមួយមិត្តភក្តិ ។ |
| ថានីអាចធ្វើការទាំងពីរ នៅពេលវិស្សមកាល ។ | ○ គេអាចទទួលបានបទពិសោធន៍ និងការហ្វឹកហ្វឺន ។<br>○ គេនឹងទទួលប្រាក់ចំណូល២ កន្លែង ដែលអាចរួមចំណែកក្នុងការរៀបអាពាហ៍ពិពាហ៍របស់បងគេ ។<br>○ គេមិនគួរមានការបង្អាក់ក្នុងការទៅសាលាហើយគួរតែធ្វើផែនការដោយផ្តោត លើការសិក្សា ។<br>○ គេនឹងមានពេលសិក្សា និង មានពេលនៅជាមួយមិត្តភក្តិរបស់គេក្នុងពេលសិក្សា ។ | ○ ថានីធ្វើការនៅពេលវិស្សមកាល មិនអាចមានប្រាក់គ្រប់គ្រាន់សម្រាប់គ្រួសារ ដើម្បីឱ្យមានស្ថេរភាពរយៈពេលយូរបានទេ ។<br>○ សម្ពាធពីគ្រួសារនឹងកើនឡើងពេញមួយវិស្សមកាល ធ្វើឱ្យគេមិនអាចឈប់ពីការងារ ហើយគេប្រឈមនឹងបញ្ហាជាថ្មីទៀតពីការសិក្សា និងការងារ ។<br>○ គេមិនអាចរកប្រាក់បានច្រើនសម្រាប់ជួយបងពេលរៀបការ ។ |
| ថានីអាចធ្វើមិនដឹងមិនឮពីគ្រួសាររបស់គេ ហើយបន្តការសិក្សាដោយមិនធ្វើការ ។ | ○ គេសប្បាយចិត្តព្រោះគេផ្តោតទៅលើ តែការសិស្សាមួយមុខប៉ុណ្ណោះ ។<br>○គេមានពេលវេលាច្រើនធ្វើកិច្ចការសាលា ។<br>○គេមានពេលសប្បាយរីករាយច្រើនជាមួយមិត្តភក្តិ ។<br>○គេផ្តោតតែទៅលើសក្តានុពលអនាគតរបស់គេ ។ | ○ គ្រួសាគេនឹងខឹងជាមួយគេ ។<br>○ គេនឹងត្រូវបណ្តេញចេញពីផ្ទះ ព្រោះពួកគេជឿថា ការសិក្សាមិនមានសារៈសំខាន់ដូចការធ្វើការងារនោះទេ ។<br>○ គេនឹងមិនមានការគាំទ្រសម្រាប់បន្តការសិក្សាតទៅទៀតទេ ។<br>○ គេមិនអាចអភិវឌ្ឍជំនាញវិជ្ជាជីវៈរបស់គេ ដែលអាចជួយឱ្យគេរកប្រាក់ចំណូលសម្រាប់ការរស់នៅរបស់គេនាពេលអនាគត ។ |

➢ ជ្រើសរើសសកម្មភាពដែលល្អបំផុត ៖

ជាមតិយោបល់មួយប្រហែលជាប្រសើរបំផុតសម្រាប់ថានី ការធ្វើការពាក់កណ្តាលពេល បើទោះបីវាមិនមែនជាការពេញចិត្តសម្រាប់ទាំងអស់គ្នាក៏ដោយ ការធ្វើបែបនេះវាផ្តល់ឱ្យនូវការសម្របសម្រួលមួយ ដែលអាចទទួលយកបាន និងជាដំណោះស្រាយស្ថិតស្ថេរយូរអង្វែង ។

| សកម្មភាពទី ៤ ៖ ការបង្កើតករណីសិក្សាស្តីពីការធ្វើសេចក្តីសម្រេចចិត្ត | ៤០ នាទី |
| --- | --- |

១. តាមឧទាហរណ៍ គ្រូបែងចែកសិស្សជាក្រុមតូចដែលមានសមាជិក៥ នាក់ ។ គ្រូណែនាំ ៖

- ក្រុមតូចនាំគ្នាបង្កើតករណីសិក្សាដោយខ្លួនឯង ។

# ឯកសារសម្រាប់គ្រូ

- សិស្សត្រូវកំណត់បញ្ហាដែលមានការលំបាកក្នុងការដោះស្រាយ
  - o វាអាចជាបញ្ហាដែលអ្នកណាម្នាក់ធ្លាប់ជួបប្រទះ
  - o បញ្ហាដែលនរណាម្នាក់ធ្លាប់ដឹង
  - o បញ្ហាដែលពួកគេគាត់តែងឡើង

- សិស្សធ្វើការជាក្រុមដើម្បី :
  - o រកដំណោះស្រាយ
  - o កំណត់សេចក្ដីសម្រេចចិត្តផ្សេងៗដែលអាចធ្វើបាន
  - o ត្រៀមធ្វើឱ្យឃើញថា ការសម្រេចចិត្តរបស់ខ្លួនគឺត្រឹមត្រូវ

- សិស្សរៀបចំការបង្ហាញ ដែលមានរយៈពេល ១០នាទី ដែលមានគំនិតដូចខាងក្រោម :
  - o តើបញ្ហាអ្វី?
  - o តើជម្រើសអ្វីខ្លះដែលអ្នកត្រូវពិចារណា?
  - o តើជម្រើសណាមួយដែលអ្នកជ្រើសរើសសម្រាប់ធ្វើការសម្រេចចិត្តនេះ?
  - o ចូរជ្រើសរើសសកម្មភាពដែលប្រសើរបំផុត
  - o ចូររៀបចំឯកសារសម្រាប់ធ្វើការពន្យល់ តើហេតុអ្វីបានជាក្រុមរបស់អ្នកគិតថាវាជាជម្រើសដ៏ល្អបំផុត ។

**កិច្ចការផ្ទះ**

- សិស្សធ្វើការតាមក្រុមតូចរបស់គេ ដើម្បីពិភាក្សាពីករណីសិក្សា សម្រាប់ធ្វើការបង្ហាញនៅម៉ោងក្រោយ ។

## មេរៀនទី៨ : អ្នកធ្វើការសម្រេចចិត្តដែលឈ្លាសវៃ

**រយៈពេលបង្រៀន** ២ ម៉ោង

**ការរៀបចំរបស់គ្រូមុនពេលបង្រៀន**

- គ្រូរំលឹកមេរៀន
- គ្រូពិនិត្យមើលសៀវភៅសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និង សំណួរ
- រៀបចំសម្ភារៈ កម្រងសំណួរ និងខ្លឹមសារមេរៀន

**សម្ភារៈ**

- ឯកសារណែនាំសម្រាប់គ្រូ
- សៀវភៅសិស្ស
- សម្ភារៈបង្រៀនដែលបានរៀបចំខាងលើ
- ក្រដាសផ្ទាំងធំសរសេរពីយុទ្ធវិធីក្នុងការធ្វើការសម្រេចចិត្ត
- ក្រដាសផ្ទាំងធំ ហ្វឺត និងបញ្ជីឈ្មោះសិស្ស
- កម្រងសំណួរ និង ខ្លឹមសារមេរៀន

**លទ្ធផលសិក្សារំពឹងទុក**

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច :

- ប្រើប្រាស់លំនាំនៃការសម្រេចចិត្តដើម្បីកំណត់ជម្រើសផ្សេងៗ និងការសម្រេចចិត្តធ្វើសកម្មភាព
- បង្កើត និង វិភាគពីគោលការណ៍នៃការធ្វើសេចក្តីសំរេចចិត្ត ។

**លំនាំនៃការបង្រៀន**

| សកម្មភាពទី១ : ក្រុមធ្វើបទបង្ហាញស្តីអំពីការធ្វើសេចក្តីសម្រេចចិត្ត | ៧០ នាទី |
|---|---|

១. គ្រូឱ្យសិស្សក្រុមតូចចាប់ផ្តើមធ្វើការបង្ហាញ

- ក្រុមនីមួយៗធ្វើការបង្ហាញមិនឱ្យលើសពី ១០នាទី ។ ការបង្ហាញត្រូវផ្តោតលើសំណួរខាងក្រោម :
    - o តើបញ្ហាអ្វី?
    - o តើជម្រើសអ្វីខ្លះដែលអ្នកបានគិតពិចារណា?
    - o តើដំណោះស្រាយអ្វីខ្លះ ដែលអ្នកបានជ្រើសរើសក្នុងការធ្វើសេចក្តីសម្រេចចិត្ត?

- ចូរពន្យល់បញ្ជាក់ តើហេតុអ្វីបានជាក្រុមរបស់អ្នកគិតថាវាជាជម្រើសល្អបំផុត?

☞ ក្រោយពីការបង្ហាញ គ្រូសួរថា

- តើអ្នកគិតថាក្រុមធ្វើការសម្រេចចិត្តបានត្រឹមត្រូវដែរឬទេ? ចូរពន្យល់?
- តើអាចមានជម្រើសផ្សេងៗទៀតដែលអ្នកគិតថាគួរពិចារណាដែរឬទេ?

| សកម្មភាពទី ២ : ការពិភាក្សាពីអ្នកធ្វើសេចក្ដីសម្រេចចិត្តដែលឈ្លាសវៃ | ៣០ នាទី |
|---|---|

**ការពិភាក្សា**

១. ក្រោយពីបញ្ចប់ការបង្ហាញ គ្រូសួរទៅសិស្ស តើមានក្រុមណាមួយមានលក្ខណៈពិសេសជាងគេក្នុងការធ្វើការសម្រេចចិត្តប្រកបដោយឈ្លាសវៃដែរឬទេ? ។ ប្រសិនបើមាន តើហេតុអ្វី ?

២. តើលក្ខណៈសម្គាល់របស់អ្នកធ្វើការសម្រេចចិត្តដែលឈ្លាសវៃមានអ្វីខ្លះ?

# ឯកសារសម្រាប់គ្រូ

## ការសង្ខេបខ្លឹមសារឯកសារស្តីពីអនាគតខ្ញុំ

គ្រូឱ្យសិស្សធ្វើការបំពេញសំណួរសង្ខេបរំលឹកមេរៀន ។ សិស្សអាចធ្វើកិច្ចការនេះដាក់ក្នុងសៀវភៅសរសេររបស់គេ ឬ គ្រូសរសេរសំណួរនៅលើក្រដាសផ្ទាំងធំ ។

- សិស្សត្រូវធ្វើកិច្ចការដោយខ្លួនឯង ដោយត្រូវឆ្លើយនឹងសំណួរដែលបិទនៅលើក្ដារខៀន ។
- សិស្សត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់កំណត់ត្រាដែលពួកគេបានធ្វើនៅក្នុងថ្នាក់រៀន ។
- សិស្សត្រូវប្រគល់កិច្ចការរបស់គេឱ្យគ្រូ ។

### សំណួរសង្ខេបរំលឹកមេរៀនសម្រាប់សិស្ស

១. តើគោលដៅជាអ្វី? ហេតុអ្វីបានជាការកំណត់គោលដៅមានសារៈសំខាន់?

២. តើមុខរបរអ្វី ដែលអ្នកចាប់អារម្មណ៍ជាងគេ? ហេតុអ្វី?

៣. តើសេចក្តីត្រូវការអ្វីខ្លះ ដែលគេត្រូវការដើម្បីឈានទៅសម្រេចមុខរបរនេះ?

៤. តើមុខរបរអ្វីដែលអ្នកចង់ដឹងបន្ថែមទៀត? តើអ្នកអាចស្វែងរកព័ត៌មានទាំងនោះដោយ របៀបណា?

៥. តើគោលដៅសំខាន់បំផុតដែលអ្នកបានកំណត់សម្រាប់ខ្លួនអ្នកជាអ្វី?

៦. កំណត់ធាតុទាំង ៤ នៃខ្លឹមសារគោលដៅរបស់អ្នកដែលអ្នកបានសរសេរខាងលើ ។

៧. ក្រោយពីអ្នកសរសេរពីខ្លឹមសារគោលដៅរបស់អ្នក តើអ្វីទៅជាផែនការសកម្មភាពគោលដៅ ដែលអ្នកត្រូវធ្វើ?

៨. តើឧបសគ្គអ្វីខ្លះដែលអ្នកមានអារម្មណ៍ថា យើងអាចជួបប្រទះនៅពេលដែលគេព្យាយាម កំណត់ និង សម្រេចគោលដៅរបស់គេ?

៩. តើដំណាក់កាលអ្វីខ្លះក្នុងលំនាំនៃការធ្វើការសម្រេចចិត្តដែលអ្នកត្រូវធ្វើតាមដើម្បីដោះស្រាយបញ្ហាប្រឈម និង ធ្វើការជ្រើសរើស?

១០. ផ្អែកលើយុទ្ធវិធី និង លក្ខណៈសម្គាល់ទូទៅដែលបានប្រើប្រាស់សម្រាប់ធ្វើការសម្រេចចិត្ត និង បានពិភាក្សានៅក្នុងថ្នាក់ តើយុទ្ធវិធីមួយណា ដែលអ្នកបានប្រើប្រាស់ក្នុងរយៈពេលកន្លងមក? សូមលើកឧទាហរណ៍បញ្ជាក់ ។

១១. តើយុទ្ធវិធីណាមួយដែលអ្នកសង្ឃឹមថា និងប្រើប្រាស់វាច្រើននាពេលអនាគត? ហេតុអ្វី?

១២. តើអ្វីដែលជាចំណុចសំខាន់បំផុតដែលអ្នកបានរៀននៅក្នុងវគ្គសិក្សានេះ?

## ឧបសម្ព័ន្ធ ១.១ : គំរូប័ណ្ណវាយតម្លៃ (សម្រាប់គ្រូប្រើ)

# ប័ណ្ណវាយតម្លៃការសិក្សារបស់សិស្សម្នាក់ៗ

ឈ្មោះសិស្ស ........................ សាលា..................... . ខេត្ត.............. ស្រុក................. ថ្នាក់ទី ........ ប្រធានបទ................

| ចំណុចត្រូវដាក់ពិន្ទុ | | ពិន្ទុ (១-១៥) | និទ្ទេស |
|---|---|---|---|
| **កិច្ចការទី ១: តេស្តចំណេះដឹង (សំណួរសរសេរ)** | | | |
| សំណួរសរសេរមានពិន្ទុសរុប ១៥ ពិន្ទុ<br>បើពិន្ទុ 0 ដល់ ៧=ខ្សោយ/ បើ ៨ ដល់ ១០=មធ្យម / បើ ១១ ដល់ ១៥=ល្អ) | | | |
| **សង្កេតឥរិយាបថសិស្ស** | | **ពិន្ទុ (១-៧)** | **និទ្ទេស** |
| ១ | **ការប្រាស្រ័យទាក់ទង និងការសហការ :** សកម្មពិភាក្សាជាមួយសមាជិកទាំងអស់ក្នុងក្រុម និងធ្វើការបានប្រសើរជាមួយក្រុម | | |
| ២ | **ការវិភាគល្អិតល្អន់ និងការដោះស្រាយបញ្ហា :** ផ្តល់ចម្លើយដោយមានហេតុផលនិងអំណះអំណាងច្បាស់លាស់ និងអាចកំណត់ ដំណោះស្រាយចំពោះបញ្ហាងាយៗដែលជួបប្រទះ។ | | |
| ៣ | **ការសម្រេចចិត្ត និងទំនុកចិត្តលើខ្លួនឯង :** មិនមានការបារម្ភច្រើន ក្នុងការធ្វើសេចក្តីសំរេចចិត្ត និងដឹងច្បាស់ថាខ្លួនគេកំពុងនិយាយឬធ្វើអ្វីមួយ។ | | |
| ៤ | **ការលើកទឹកចិត្ត និងការយល់ចិត្ត:** សិស្សចង់បន្តរៀនសូត្របន្ថែមពីបញ្ហានេះ និងយល់ពីមូលហេតុដែលសមាជិកក្រុមមានការលំបាកក្នុងការចូលរួម។ | | |
| ៥ | **ចរិត និងការបង្កើតថ្មី:** មានចិត្តអំណត់ និងអារម្មណ៍ល្អ និងមានគំនិតផ្ទាល់ខ្លួនច្រើន។ | | |
| | **សរុបការសង្កេតឥរិយាបថសិស្ស** | | |
| សង្កេតឥរិយាបថសិស្សមានពិន្ទុសរុប ៣៥ ពិន្ទុ<br>( បើពិន្ទុ 0 ដល់ ១៧ =ខ្សោយ/ បើ ១៨ ដល់ ២៣=មធ្យម / បើ ២៤ ដល់ ៣៥=ល្អ) | | | |
| ពិន្ទុសរុបសំណួរសរសេរ និងសង្កេតឥរិយាបថសិស្ស<br>( បើពិន្ទុ 0 ដល់ ២៤=ខ្សោយ/ បើ ២៥ ដល់ ៣៣=មធ្យម / បើ ៣៤ ដល់ ៥០=ល្អ) | | | |

ថ្ងៃទី .......... ខែ ........... ឆ្នាំ ..........

ហត្ថលេខា និងឈ្មោះគ្រូ

## ឧបសម្ព័ន្ធ ១.២ : តារាងបូកសរុបរបាយតម្លៃការសិក្សារបស់សិស្សប្រចាំថ្នាក់

ខេត្ត ......................... ស្រុក ........................សាលា .............................. ថ្នាក់ទី .......... ប្រធានបទ ....................

| ល.រ | ឈ្មោះសិស្ស | សំណួរសរសេរ | | ឥរិយាបថ | | សរុប | |
|---|---|---|---|---|---|---|---|
| | | ពិន្ទុ | និទ្ទេស | ពិន្ទុ | និទ្ទេស | ពិន្ទុ | និទ្ទេស |
| ១ | | | | | | | |
| ២ | | | | | | | |
| ៣ | | | | | | | |
| ៤ | | | | | | | |
| ៥ | | | | | | | |
| ៦ | | | | | | | |
| ៧ | | | | | | | |
| ៨ | | | | | | | |
| ៩ | | | | | | | |
| ១០ | | | | | | | |
| ១១ | | | | | | | |
| ១២ | | | | | | | |
| ១៣ | | | | | | | |
| ១៤ | | | | | | | |
| ១៥ | | | | | | | |
| ១៦ | | | | | | | |
| ១៧ | | | | | | | |
| ១៨ | | | | | | | |
| ១៩ | | | | | | | |
| ២០ | | | | | | | |
| ២១ | | | | | | | |
| ២២ | | | | | | | |
| ២៣ | | | | | | | |
| ២៤ | | | | | | | |
| ២៥ | | | | | | | |
| ២៦ | | | | | | | |

បានឃើញ និងឯកភាព

ថ្ងៃទី .......... ខែ ............ ឆ្នាំ ..........

នាយកសាលា

ហត្ថលេខា និងឈ្មោះគ្រូបង្រៀន

**ឧបសម្ព័ន្ធ ២ :** **ទម្រង់វាយតម្លៃគ្រូបង្រៀនបំណិនជីវិត**

ខេត្ត/ក្រុង ........................... ស្រុក/ខណ្ឌ ..................................... ឃុំ/សង្កាត់ .....................................

កម្រងសាលារៀន ........................... សាលារៀន ................................ ឈ្មោះគ្រូ .................................. ភេទ ........

ថ្នាក់ទី .............. ប្រធានបទ ................................................................... មេរៀន ..................................

ចំនួនសិស្សវត្តមាន ................ ស្រី ............. កាលបរិច្ឆេទវាយតម្លៃ : ថ្ងៃទី ........... ខែ .............. ឆ្នាំ ............

| **ខ្លឹមសារ** | **ពិពណ៌នាសកម្មភាព** | **កត់ត្រាផ្សេងៗ** |
|---|---|---|
| **I- បន្ទប់រៀន :** ការរៀបចំតុបតែង-រដ្ឋបាលថ្នាក់របស់គ្រូ | | |
| **១.១.ការតុបតែង និង ដាក់តាំងសម្ភារៈ**<br><br>**លទ្ធផល**<br>☐ | ☐ មានរៀបចំតុបតែង បាវចនាជាតិ ព្រះឆាយាលក្ខណ៍ និង ពាក្យស្លោកអប់រំ | |
| | ☐ មានតារាងផ្សេងៗ និង មានខ្លឹមសារបិទតាំងយ៉ាងត្រឹមត្រូវ | |
| | ☐ មានរូបភាព ផ្ទាំងសំណេរដាក់តាំងត្រឹមត្រូវតាមកំពស់សិស្ស | |
| | ☐ មានរូបភាពតាមមុខវិជ្ជា និង សម្ភារឧបទេសដាក់តាំងតាមជញ្ជាំង តាមកៀនសិក្សាតាមមុខវិជ្ជាងាយស្រួលយកមកប្រើ | |
| | ☐ មានដាក់តាំងបង្ហាញស្នាដៃសិស្ស (រូបភាព កិច្ចការ ឧបករណ៍...) | |
| **១.២.ការរៀបចំបង្គុយសិស្ស និងក្ដារខៀន**<br>**លទ្ធផល**<br>☐ | ☐ គ្រូបានរៀបចំបង្គុយសិស្សស្របតាមខ្លឹមសារមេរៀន និងសកម្មភាពរៀន និងបង្រៀន | |
| | ☐ តុសិស្សមានចំនួនសមស្របទៅនឹងចំនួនសិស្ស | |
| | ☐ តុសិស្សទាំងអស់ត្រូវបានថែទាំ និងរៀបចំដោយមានរបៀបរៀបរយល្អ | |
| | ☐ តុសិស្សមានកំពស់សមស្របតាមវ័យរបស់សិស្ស | |
| | ☐ បន្ទប់រៀនត្រូវបានសំអាតជាប្រចាំ និង គ្មានសង្ហារឹមបាក់បែក ក្នុងបន្ទប់ | |
| | ☐ មានក្ដារខៀន ធំ-តូច សម្រាប់ប្រើប្រាស់ក្នុងសកម្មភាពរៀន និង បង្រៀន | |
| **១.៣.ការងាររដ្ឋបាលរបស់គ្រូ**<br><br>**លទ្ធផល**<br>☐ | ☐ គ្រូបានស្រង់វត្តមានសិស្សជាប្រចាំ ហើយបញ្ជាក់មូលហេតុច្បាស់លាស់ ដោយមានចុះទិដ្ឋាការនាយកសាលា | |
| | ☐ គ្រូបានចុះពិន្ទុសិស្សរៀនបំណិនជីវិតគ្រប់ចំនួន និងបូកស្រង់ យ៉ាងត្រឹមត្រូវ ព្រមទាំងមានទិដ្ឋាការរបស់នាយក | |
| | ☐ គ្រូបានបំពេញសៀវភៅតាមដានការសិក្សារបស់សិស្ស យ៉ាងត្រឹមត្រូវ និង បញ្ជូនទៅមាតាបិតាសិស្សយ៉ាងទៀងទាត់រៀងរាល់ខែ | |
| | ☐ គ្រូបានប្រើប្រាស់សៀវភៅទំនាក់ទំនងចំពោះសិស្សដែលមានបញ្ហា (ឈប់ច្រើន គេចសាលា ...) ជាមួយមាតាបិតាសិស្សជាប្រចាំ | |
| | ☐ គ្រូបានកត់ខ្លឹមសារសំខាន់ៗ នៅក្នុងសៀវភៅផ្សេងៗ ដើម្បីយក ទៅអនុវត្ត ក្រោយពេលប្រជុំ ការណែនាំ ការចូលរួម ... | |
| | ☐ គ្រូបានថែទាំ ទុកដាក់ឯកសារបំណិនជីវិត (ផូស្ទ័រគ្រូ ផូស្ទ័រសិស្ស ស្នាដៃសិស្ស ឯកសារសិស្ស) ព័ត៌មានរបស់សិស្ស និងឯកសារផ្សេងៗបានល្អ | |
| **II- ការបង្រៀន និង រៀន** | | |
| **២.១.ការរៀបចំកិច្ចតែង ការបង្រៀន**<br><br>**លទ្ធផល**<br>☐ | ☐ គ្រូបង្រៀនបានរៀបចំកិច្ចតែងការបង្រៀនជាប្រចាំ | |
| | ☐ កិច្ចតែងការបង្រៀន មានការកំណត់វត្ថុបំណងច្បាស់លាស់ស្របតាមខ្លឹមសារមេរៀន | |
| | ☐ សកម្មភាពក្នុងកិច្ចតែងការបង្រៀន ឆ្លើយតបទៅនឹងវត្ថុបំណងនៃមេរៀន | |
| | ☐ កិច្ចតែងការបង្រៀនមានលក្ខណៈពេញលេញ (ខ្លឹមសារ-សកម្មភាពគ្រូ -សកម្មភាពសិស្ស) | |
| | ☐ កិច្ចតែងការបង្រៀន មានចុះទិដ្ឋាការរបស់នាយក | |

| | | |
|---|---|---|
| | ☐ កិច្ចតែងការមានខ្លឹមសារស្វ័យវាយតម្លៃរបស់គ្រូ | |
| **២.២.ការអនុវត្តកិច្ចតែងការបង្រៀន**<br>**លទ្ធផល**<br>☐ | ☐ គ្រូបានប្រើប្រាស់កិច្ចតែងការបង្រៀន គ្រប់សកម្មភាពក្នុងម៉ោងសិក្សា | |
| | ☐ គ្រូបានប្រើប្រាស់ពេលវេលា សមស្របតាមជំហាននីមួយៗ | |
| | ☐ គ្រូបានអនុវត្តការងារតាមលំនាំសកម្មភាពច្បាស់លាស់ ( ក្រុមតូច ក្រុមធំ ) | |
| | ☐ គ្រូបានប្រើប្រាស់សកម្មភាពក្នុងកិច្ចតែងការបង្រៀន ដោយផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅ និង ស្ថានភាពជាក់ស្តែងថែមទៀត | |
| | ☐ គ្រូបានព្យាយាមកែលំអ សកម្មភាពដឹកនាំឱ្យបានកាន់តែប្រសើរចំពោះសកម្មភាពណាដែលមិនសូវច្បាស់លាស់ | |
| | ☐ គ្រូបានធ្វើស្វ័យវាយតម្លៃលើកិច្ចតែងការបង្រៀន | |
| **២.៣.ការចាត់តាំងសកម្មភាពរៀន និង បង្រៀន**<br>**លទ្ធផល**<br>☐ | ☐ គ្រូបានចាត់តាំងសកម្មភាពសិស្ស-ក្រុមសិស្ស ក្នុងថ្នាក់ ក្រៅថ្នាក់ តម្រូវតាមខ្លឹមសារមេរៀន | |
| | ☐ គ្រូបានរៀបចំសកម្មភាពសិស្សដោយចម្រុះភេទ និង សមត្ថភាព | |
| | ☐ គ្រូបានណែនាំសិស្ស និងក្រុមសិស្សបានច្បាស់លាស់រាល់ ពេលមុនធ្វើសកម្មភាព | |
| | ☐ សមាជិកក្នុងក្រុមនីមួយៗបានចូលរួមយ៉ាងសកម្ម និងមានការទទួលខុសត្រូវ( សួរសំណួរ-ផ្តល់យោបល់-បកស្រាយ-រាយការណ៍-កត់ត្រា ... ) | |
| | ☐ សកម្មភាពអនុវត្តរបស់សិស្ស ឆ្លើយតបទៅនឹងវត្ថុបំណងរបស់មេរៀន | |
| **២.៤.ការប្រើប្រាស់សំណួរ**<br>**លទ្ធផល**<br>☐ | ☐ គ្រូបានផ្តោតលើការប្រើប្រាស់សំណួរយល់ដឹង និង ពិចារណាហ្មត់ចត់លើរាល់ខ្លឹមសារនៃមេរៀន ដើម្បីអភិវឌ្ឍការគិតរបស់សិស្ស | |
| | ☐ គ្រប់សំណួររបស់គ្រូ ស្របតាមកម្រិតយល់ដឹងរបស់សិស្ស និង ខ្លឹមសារមេរៀន | |
| | ☐ គ្រូបានព្យាយាមប្រើប្រាស់សំណួរបន្ថែម ដើម្បីបំពេញ និងពង្រឹងការយល់ដឹងរបស់សិស្ស | |
| | ☐ គ្រូបានផ្តល់ឱកាសឱ្យសិស្ស ក្រុមសិស្សសួរគ្រូ( ពេលមិនយល់ ឬ មិនច្បាស់លាស់ ) | |
| | ☐ គ្រូបានផ្តល់ឱកាសឱ្យសិស្ស ក្រុមសិស្ស សាកសួរគ្នាទៅវិញ ទៅមក ដើម្បីបញ្ជាក់ភាពច្បាស់លាស់របស់គេ | |
| **២.៥.ការប្រើប្រាស់សម្ភារឧបទេសក្នុងការរៀន និងបង្រៀន**<br>**លទ្ធផល**<br>☐ | ☐ គ្រូ និង សិស្សបានត្រៀមសម្ភារឧបទេសគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់តាមក្រុម និង តាមសកម្មភាព | |
| | ☐ គ្រូបានរៀបចំសម្ភារឧបទេស និងប្រើប្រាស់តាមលំដាប់លំដោយនៃខ្លឹមសារមេរៀន និងសកម្មភាព | |
| | ☐ គ្រូបានប្រើប្រាស់ធនធានសម្ភារៈក្នុងបន្ទប់រៀន ផ្សារភ្ជាប់ទៅនឹង ខ្លឹមសារមេរៀន | |
| | ☐ គ្រូបានប្រើប្រាស់សម្ភារៈច្នៃប្រឌិត និងធនធានងាយៗ សម្រាប់ការរៀន និងបង្រៀន | |
| | ☐ គ្រូបានឱ្យសិស្សប្រើប្រាស់សម្ភារឧបទេសដោយផ្ទាល់ និងណែនាំ ពីងាយទៅលំបាក | |
| **២.៦.ការប្រើប្រាស់ឯកសារសិស្ស ថូស្ស័រសិស្ស និងឯកសារផ្សេងៗ**<br>**លទ្ធផល**<br>☐ | ☐ គ្រូបានឱ្យសិស្សប្រើប្រាស់ឯកសារសិស្ស ដើម្បីធ្វើការស្រាវជ្រាវ | |
| | ☐ សិស្សភាគច្រើនមានឯកសារប្រើប្រាស់ក្នុងម៉ោងសិក្សា | |
| | ☐ សិស្សបានថែទាំ និងប្រើប្រាស់ឯកសារបំណិនជីវិតយ៉ាងត្រឹមត្រូវតាមការណែនាំ | |
| | ☐ គ្រូ និង សិស្សបានប្រើប្រាស់ឯកសារផ្សេងៗ ដើម្បីស្រាវជ្រាវសម្រាប់បំពេញបន្ថែមក្នុងខ្លឹមសារមេរៀនដែលមានក្នុងសៀវភៅបំណិនជីវិត | |
| | ☐ គ្រូបានដាក់កិច្ចការ ដើម្បីឱ្យសិស្សធ្វើការស្រាវជ្រាវ និងសិក្សាបន្ថែមនៅបណ្ណាល័យ ឬ នៅក្នុងសហគមន៍ | |

| | | |
|---|---|---|
| | | |
| **២.៧.សកម្មភាពពង្រីកបន្ថែម និងការបញ្ជ្រាបមេរៀនទៅក្នុងមុខវិជ្ជាដទៃ** | ☐ គ្រូបានរៀបចំសកម្មភាពផ្សេងៗ (ល្បែងសិក្សា-ល្បែងដើរតួ-ចម្រៀង-លំហាត់ប្រាណ ... ) ដើម្បីពង្រីកបន្ថែមក្នុងមេរៀន | |
| | ☐ គ្រូបានចាត់តាំងឱ្យមានការពិសោធ ស្រាវជ្រាវ សង្កេត សម្ភាសន៍ ដើម្បីពង្រឹង និង អភិវឌ្ឍន៍សមត្ថភាពសិស្ស | |
| **លទ្ធផល** | ☐ គ្រូបានបញ្ជ្រាបខ្លឹមសារមេរៀន ដោយផ្សារភ្ជាប់ពីមុខវិជ្ជាមួយទៅមុខវិជ្ជាដទៃទៀត | |
| ☐ | ☐ គ្រូបានឱ្យសិស្សប្រមូលព័ត៌មានផ្សេងៗនៅខាងក្រៅ ដើម្បីតម្រូវទៅនឹងខ្លឹមសារមេរៀន ដែលមានក្នុងឯកសារបំណិនជីវិតរបស់សិស្ស | |
| | ☐ គ្រូបានបង្រៀនមេរៀន ដោយផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅរបស់សហគមន៍ និង មូលដ្ឋាន | |
| **២.៨.ការដាក់កិច្ចការ និងការជួយសិស្សរៀនយឺត** | ☐ គ្រូបានដាក់កិច្ចការស្របតាមសមត្ថភាពសិស្ស ជាពិសេសសិស្សរៀនយឺត | |
| | ☐ គ្រូបានសិក្សាច្បាស់លាស់ នូវស្តង់ដាកម្មវិធីសិក្សា សម្រាប់ការដាក់កិច្ចការ ឬ ធ្វើតេស្ត សម្រាប់ដាក់ពិន្ទុប្រចាំខែ ឬ ឆមាស | |
| **លទ្ធផល** | ☐ គ្រូបានពិនិត្យ និងកែកិច្ចការសិស្សបានត្រឹមត្រូវ និងទៀងទាត់ | |
| ☐ | ☐ គ្រូបានព្យាយាមជួយសិស្សរៀនយឺត និងកែលំអរាល់ចំណុចខ្វះខាត | |
| | ☐ គ្រូបានរៀបចំសិស្សពូកែតាមមុខវិជ្ជា ដើម្បីជួយសិស្សរៀនយឺត | |
| **២.៩.បរិយាកាសថ្នាក់រៀន និងការលើកទឹកចិត្ត** | ☐ គ្រូបានប្រើប្រាស់ភាសាទំនាក់ទំនងយ៉ាងទន់ភ្លន់ និង ស្និទ្ធស្នាល ចំពោះសិស្សគ្រប់រូបដោយមិនរើសអើង | |
| | ☐ គ្រូមិនស្តីបន្ទោស ឬ ធ្វើទណ្ឌកម្មសិស្ស និង ព្យាយាមកែលំអពេលសិស្សឆ្លើយខុស ឬ ធ្វើអ្វីមួយខុស | |
| **លទ្ធផល** | ☐ គ្រូព្យាយាមជម្រុញ និងលើកទឹកចិត្តសិស្សដែលបានបញ្ចេញ យោបល់ ឬ សាកសួរ ឬ ឆ្លើយត្រូវ ឬ ធ្វើកិច្ចការមួយបានល្អ និង យកចម្លើយល្អទាំងនោះសម្រាប់កសាងខ្លឹមសារមេរៀនសង្ខេប | |
| ☐ | ☐ គ្រូព្យាយាមមកក្បែរ ឬ សំដែងការយកចិត្តទុកដាក់គ្រប់ពេល ចំពោះសិស្សរៀនយឺត និង សិស្សដែលជួបការលំបាក | |
| | ☐ គ្រូបានយកចិត្តទុកដាក់អប់រំណែនាំសិស្សជាប្រចាំ ដើម្បីបំបាត់ ភាពរើសអើងក្នុងថ្នាក់រៀន( ការសើច-ការធ្វើកាយវិការចំអក-ការបន្តុះបង្អាប់-ការប្រមាថមើលងាយ-ការបង្កជម្លោះ ...) | |
| **២.១០.ការដាក់កិច្ចការផ្ទះ** | ☐ គ្រូបានដាក់កិច្ចការឱ្យសិស្សធ្វើនៅផ្ទះ យ៉ាងទៀងទាត់ | |
| | ☐ ខ្លឹមសារនៃសំណួរ ឬ លំហាត់សមស្របទៅនឹងកម្រិតយល់ដឹងរបស់សិស្ស | |
| **លទ្ធផល** | ☐ សំណួរ និងលំហាត់មានលក្ខណៈពង្រឹងចំណេះដឹង និងការស្រាវជ្រាវបន្ថែមក្រៅម៉ោងសិក្សា | |
| ☐ | ☐ គ្រូបានត្រួតពិនិត្យ និង កែកិច្ចការផ្ទះរបស់សិស្សជាប្រចាំ | |
| | ☐ សិស្សម្នាក់ៗមានសៀវភៅកិច្ចការ និង បានប្រើប្រាស់-ថែទាំ យ៉ាងត្រឹមត្រូវ ។ | |

**ក្រុមពិនិត្យតាមដាន**

១- លោក/លោកស្រី .............................. ហត្ថលេខា...........

២- លោក/លោកស្រី .............................. ហត្ថលេខា............ .

| |
|---|
| ពិន្ទុផ្នែកបន្ទប់រៀន : ..................../១៧ |
| ពិន្ទុផ្នែកការបង្រៀន និងរៀន : ....................../៥២ |
| ពិន្ទុសរុប : ............................/៦៩ |

**យោបល់របស់គ្រូបង្រៀន**

...........................................................

...........................................................

...........................................................

ហត្ថលេខា

ឈ្មោះគ្រូបង្រៀន

# ស្ថានភាពគ្រោះថ្នាក់ និងគ្មានអនាម័យ



ធ្វើការជាមួយជាតិគីមីគ្រោះថ្នាក់

ធ្វើការជាមួយម៉ាស៊ីនគ្រោះថ្នាក់





បាញ់ថ្នាំសម្លាប់សត្វល្អិត



បន្ទប់ទឹកគ្មានអនាម័យ និងមិនមានបង្គន់គ្រប់គ្រាន់សម្រាប់ស្ត្រី

ធ្វើការនៅកន្លែងដែលសម្លេងខ្លាំង





ធ្វើការនៅកន្លែងបិទជិត និងមិនមានខ្យល់អាកាសល្អចេញចូល



ធ្វើការនៅក្នុងផ្ទះដែលមានកន្លែងអង្គុយមិនសមរម្យ



កុមារ និងមនុស្សវ័យជំទង់ធ្វើការនៅកន្លែងនេសាទ និងអណ្តូងរ៉ែ

កុមារធ្វើការជាការបម្រើនៅតាមផ្ទះ



ក្រសួងកិច្ចការនារី

MINISTERIO
DE ASUNTOS EXTERIORES
Y DE COOPERACIÓN

aecid

កិច្ចសហប្រតិបត្តិការ
អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

giz Deutsche Gesellschaft
für Internationale
Zusammenarbeit (GIZ) GmbH